ទស្សនាវដ្ដី ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២០ លេខ ២៣៧ ខែកុម្ភៈ ឆ្នាំ ២០២១



សម្តេចតេជោ ហ៊ុន សែន ៖ ជំនួយវ៉ាក់សាំងការពារជំងឺកូវីដ១៩ ជាសក្ខីភាព.....

៥

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ៖ គ្រើនរំលឹកយុវជនជំនាន់ក្រោយឲ្យខិតខំរៀនសូត្រដើម្បីអនាគត....

៨

សម្តេចក្រឡាហោម ស ខេង ៖ណែនាំកិច្ចការសំខាន់ជាអទិភាពឆ្ពោះទៅកាន់ការបោះឆ្នោត...

៩

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ៖ កត្តាដែលនាំឲ្យយើងទទួលបានជ័យជម្នះ គឺសាមគ្គីភាព និងឯកភាពផ្ទៃក្នុង...

១០

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេង ខន** ៖ ការកសាងសហគមន៍ជោគវាសនារួមកម្ពុជា-ចិន កាន់តែមានសន្ទុះខ្លាំងក្លា....

១១

គ្របមុខ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាជំនួយរបស់រាជរដ្ឋាភិបាលចិន

ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១

មាតិកា
Contents

វិចារណកថា : កម្ពុជាមានសុទិដ្ឋិនិយមចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមឆ្នាំ២០២១........................... 0១

Editorial : Cambodia is optimistic about socio-economic development in 2021.......................... 09

⇨ អត្ថបទនយោបាយ: ពង្រឹងជំនឿទុកចិត្តចំពោះការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែល............ 0៤

⇨ សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្រ្តីគណបក្ស ១២

⇨ សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៦

⇨ សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច.. ១៨

⇨ វិស័យកសិកម្មនៅតែជាគោលដៅចំបង ដើម្បីធានាសន្តិសុខស្បៀង អាហារូបត្ថម្ភ........................ ១៩

⇨ ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មឲ្យកាន់តែមានសន្ទុះខ្លាំងក្នុងឆ្នាំ ២០២១ .... ២១

⇨ អត្ថបទវប្បធម៌: ប្រវត្តិរូបសំណាកដំរីជាន់ខ្លាខេត្តកំពង់ធំ.. ២៣

⇨ ចំណេះដឹងទូទៅ: ការព្យាករណ៍កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២១ នៅតែមិនទាន់............... ២៤

⇨ ទឹកដី មាតុភូមិ:ស្រុកមួយដែលនៅជាប់នឹងបឹងទន្លេសាប.. ២៥

⇨ កំណាព្យ: ទេវតា និងកូវីដ................................សំណើច... ២៨

និពន្ធនាយក :

លោក តាត ស៊ុនអ៊ី

គណៈកម្មការនិពន្ធ

១. លោក ខៀវ ណារី

២. លោក អ៊ុម សុន្ទរៈ

៣. លោក វង្ស សាវុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

លេខានិពន្ធ

១. លោក ស្វាយ ភីរុណ

២. លោក ម៉ក់ ឈិន

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័គ

អ្នកថតរូប

១. លោក សុផាត វីរៈមុនី

វិចិត្រករ

១. លោក ធា សាវុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

0២៣ ២១៩ 0៦៥

Address :

No 203 Preah Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

វិចារណកថា EDITORIAL

កម្ពុជាមានសុទិដ្ឋិនិយមចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឆ្នាំ២០២១

Cambodia is optimistic about socio-economic development in 2021

ឆ្នាំ២០២១ គឺជាឆ្នាំទី៣ នៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ជាឆ្នាំដែលយើងទាំងអស់គ្នាត្រូវខិតខំពុះពារទ្វេដង ដើម្បីឆ្លងឲ្យផុតនូវឧបសគ្គទាំងឡាយ ដែលបង្កឡើងពីវិបត្តិនៃជំងឺកូវីដ-១៩ កាលពីអំឡុងឆ្នាំ២០២០កន្លងទៅ ។ ការរាតត្បាតនៃជំងឺដ៏កាចសាហាវនេះ បានធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំង ចំពោះសកលលោកទាំងមូល និយាយជារួម និងដោយឡែក ប្រទេសកម្ពុជាយើងក៏ទទួលរងនូវវិបត្តិដ៏អាក្រក់នេះ បង្កផលប៉ះពាល់ជាអវិជ្ជមានមកលើវិស័យសេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ ។ ចក្ខុវិស័យរបស់កម្ពុជា ក្នុងកិច្ចដំណើរការអភិវឌ្ឍឈានឡើង ប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ ក៏ត្រូវបានបន្ទុចបង្អាក់ ។ ប៉ុន្តែអាស្រ័យដោយរាជរដ្ឋាភិបាលគ្រប់គ្រងបានទាំងស្រុង និងប្រកបដោយប្រសិទ្ធភាពនូវវិបត្តិនេះ ក្នុងឆ្នាំ២០២០ធ្វើឲ្យ យើងនៅតែមានលទ្ធភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កាត់បន្ថយបានហានិភ័យទាំងឡាយ និងបង្កភាពអនុគ្រោះសម្រាប់ការបោះជំហានទៅមុខទៀតលើវិថីនៃការអភិវឌ្ឍ សម្រាប់ឆ្នាំ២០២១នេះ និងបណ្ដាឆ្នាំខាងមុខ ។

*ទោះបីជាវ៉ាក់សាំងការពារជំងឺកូវីដ១៩ ត្រូវបានដាក់ឲ្យប្រើប្រាស់ក្នុងពិភពលោករាប់ទាំងប្រទេសកម្ពុជាផងប៉ុន្តែមកដល់ពេលនេះមិនទាន់មានស្ថាប័នណាមួយ ឬបុគ្គលណាម្នាក់អាចធ្វើការវាយតម្លៃ ឬព្យាករណ៍ឲ្យបានប្រាកដប្រជាថា តើជំងឺកូវីដ-១៩នឹងត្រូវបញ្ចប់នៅពេលណា? ផលវិបាកដែលបង្កឡើងពីវិបត្តិនេះនឹងជះឥទ្ធិពលរយៈពេលយូរប៉ុណ្ណា និងមានទំហំធំយ៉ាងណា ក៏មិនទាន់អាចសន្និដ្ឋានបាន។ ប៉ុន្តែក្នុងតំណាក់កាលនេះ បណ្ដាប្រទេសទាំងអស់ ក៏បានដាក់ចេញនូវវាល់វិធានការដោះស្រាយ ការធ្វើអន្តរាគមន៍តាមរយៈការប្រើប្រាស់នូវឧបករណ៍គោលនយោបាយនានាទៅតាមភាពជាក់ស្ដែងនៃស្ថានភាពប្រទេសនីមួយៗ ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការយ៉ាងម៉ឹងម៉ាត់ និងម៉ត់ចត់បំផុត ក្នុងការដាក់ចេញគោល-នយោបាយ និងយុទ្ធសាស្ត្រជាតិ ដឹកនាំអនុវត្តផែនការសកម្មភាព ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ការទ្រទ្រង់ និងរក្សាសុខភាពសេដ្ឋកិច្ចសង្គមក្នុងដំណាក់កាលកូវីដ-១៩ និងការត្រៀមសម្រាប់ការស្ដារសេដ្ឋកិច្ចជាតិឲ្យមានកំណើនឡើងវិញ ក្រោយវិបត្តិនៃជំងឺសកលដ៏កាចសាហាវនេះ ។ ក្រោមការដឹកនាំរបស់***សម្ដេចតេជោ ហ៊ុន សែន*** *រាជរដ្ឋាភិបាលកម្ពុជា បានខិតខំលើកកម្ពស់ស្មារតីនៃការចូលរួមរបស់ប្រជាជាតិទាំងមូល ដើម្បីធ្វើយ៉ាងណាសម្រេចឲ្យបានទិសដៅនៃការអភិវឌ្ឍសម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២១នេះ និងបណ្ដាឆ្នាំខាងមុខ ។ ជាក់ស្ដែង ក្របខណ្ឌនៃផែនការស្ដារសេដ្ឋកិច្ចកម្ពុជា ក្រោយវិបត្តិកូវីដ-១៩ សម្រាប់ឆ្នាំ២០២១-២០២៣ ផ្ដោតលើអភិក្រមចំនួន ៣ គឺ* ***១-*** *យុទ្ធសាស្ត្រដើម្បីរស់ ដោយជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចផង និងបន្តប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ផង ។ រាជរដ្ឋាភិបាលបន្តអនុវត្តនូវរាល់ជំនួយសង្គម និងការដាក់ចេញវិធានការអន្តរាគមន៍បន្ទាន់* ***២-*** *ការកែទម្រង់ ដោយធ្វើឲ្យប្រសើរឡើងនូវបរិយាកាសនៃការវិនិយោគ និងធុរកិច្ច ជំរុញការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ដើម្បីប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ឲ្យទៅជាឱកាស និង****ទី៣-***

The year 2021 is the third year of the implementation of the Royal Government of Cambodia's political platform for the sixth legislature of the National Assembly, and a year in which we must all redouble efforts to overcome the obstacles posed by the Covid-19 crisis during the year 2020. The devastating epidemic has taken a toll on the entire world as a whole, and in particular, Cambodia has suffered from this devastating crisis, adversely affecting the economy, society and daily life of the people, especially the poor and vulnerable. Cambodia's vision for the development process to become a high-middle-income country by 2030 and a high-income country by 2050 has also been hampered. However, with the Royal Government fully and effectively managing this crisis in 2020, we will still be able to develop socio-economically, reduce risks and create favorable conditions for further progress on the path of development, for this year 2021 and the years to come.

Although Covid-19 vaccine has been introduced worldwide, including in Cambodia, so far no institution or individual has been able to accurately assess or predict as to when the Covid-19 will be over. It is unknown at this time as to how long and large the adverse consequences will be. However, at this stage, every countries have put in place measures to address the intervention through use of policy tools according to the realities of each country's situation. The Royal Government of Cambodia has taken the strictest and most drastic measures in the formulation of national policies and strategies to guide the implementation of the action plan to prevent Covid-19, to support and maintain socio-economic health during Covid-19, and to prepare for economic recovery after the devastating pandemic crisis. Under the leadership of Samdech Techo Hun Sen, the Royal Government of Cambodia strives to promote the spirit of participation of the entire nation in order to achieve the development goals for Cambodia's economic growth in 2021 and in the years to come.

In fact, the framework of Cambodia's post-Covid-19 crisis economic recovery plan for 2021-2023 focuses on three approaches. Firstly, uphold strategies for survival by promoting economic recovery and continuing to fight Covid-19. The Royal Government continues to implement all social assistance and the introduction of urgent intervention measures. Secondly, conduct reforms by i mproving the investment and business environment, promoting the development of digitalized economic

ការកសាងភាពធន់ប្រកបដោយចីរភាព និងបរិយាប័ន តាមរយៈការកសាង និងពង្រឹងសមត្ថភាពស្ថាប័ន ការបង្កើននូវប្រភពធនធានមនុស្ស និងហិរញ្ញវត្ថុ ពង្រឹងភាពប្រកួតប្រជែង និងការកសាងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុករឹងមាំ ។

ក្នុងឆ្នាំ២០២១នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងងើបឡើងវិញ ហើយរំពឹងថា នឹងសម្រេចបានកំណើនក្នុងរង្វង់ ៤% ដែលធ្វើឱ្យ ផ.ស.ស ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ ១១៧.៩៣៩ ប៊ីលានរៀល សមមូលនឹងប្រមាណ ២៩.០១៣ លានដុល្លារអាមេរិក ស្របពេលដែល ផ.ស.ស. សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថា នឹងកើនឡើងដល់ ១.៧៧១ ដុល្លារអាមេរិក បើប្រៀបធៀបនឹង១.៦៨៣ដុល្លារអាមេរិកក្នុងឆ្នាំ២០២០។កំណើននេះគាំទ្រដោយការងើបឡើងវិញនៃវិស័យសេដ្ឋកិច្ចសំខាន់ៗដូចជា៖វិស័យកសិកម្មត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងអត្រា ១,៦% ដោយសារការកើនឡើងនៃអនុវិស័យដំណាំ អនុវិស័យចិញ្ចឹមសត្វ និងអនុវិស័យនេសាទ, វិស័យឧស្សាហកម្មត្រូវបានព្យាករណ៍ថា នឹងងើបឡើងវិញក្នុងអត្រាកំណើន ៤,១% ពីកំណើនអវិជ្ជមាន ដោយសារការរំពឹងទុកនូវការងើបឡើងវិញក្នុងកម្រិតទាបនៃអនុវិស័យកាត់ដេរ និងអនុវិស័យសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរត្រូវបានរំពឹងថា នៅរក្សាបានកំណើនល្អ ប្រសើរ និងវិស័យសេវាកម្មត្រូវបានព្យាករណ៍ថា នឹងមានកំណើនក្នុងអត្រា ៤% ដោយសារការរំពឹងទុកនៃការងើបឡើងវិញ ក្នុងកម្រិតទាបនៃសកម្មភាពសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យទេសចរណ៍ និងការប្រើប្រាស់ក្នុងស្រុក បន្ទាប់ពីវិបត្តិកូវីដ-១៩ ។ អតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវបានប៉ាន់ស្មានថា ស្ថិតនៅក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ៣,១% ដោយសារការរំពឹងទុកនៃការងើបឡើងថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីការធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ២០២០ ។ ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករណ៍ថា នឹងរួមតូចបន្តិចមកត្រឹម ១៧,៣% នៃផ.ស.ស ដោយសារការរំពឹងនៃការងើបឡើងសន្សឹមៗនូវការនាំចេញ និងវិស័យទេសចរណ៍ ។ ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថា នឹងកើនឡើងដល់ ១៦.៩៨១លានដុល្លារអាមេរិក និងធានាការនាំចូលបាន ៨ខែ ដោយហេតុថា ការនាំចូលរបស់កម្ពុជាក៏នឹងងើបឡើងបន្តិចវិញ ។

ទោះបីប្រឈមឧបសគ្គ និងការលំបាកច្រើន ប៉ុន្តែយើងនៅតែមានសុទិដ្ឋិនិយមចំពោះការអភិវឌ្ឍ សម្រាប់ឆ្នាំ២០២១នេះ ដោយសារយើងមានលក្ខខណ្ឌអនុគ្រោះជាច្រើន ។ ក្នុងឆ្នាំ២០២០ កម្ពុជា ទោះជាត្រូវទទួលរងការផលវិបាកនៃជំងឺកូវីដ-១៩ ប៉ុន្តែយើងគ្រប់គ្រងបានប្រកបដោយប្រសិទ្ធភាព ដោយគ្មានករណីស្លាប់ គ្មានការដាក់ប្រទេសក្នុងគ្រាមានអាសន្ន មិនមានការបិទជាតំបន់ ឬប្រទេសទាំងមូលឡើយ ។ រាជរដ្ឋាភិបាលបានធ្វើឲ្យទទួលជោគជ័យចំពោះការប្តេជ្ញាចិត្ត ក្នុងការរក្សាបាននូវភាពម្ចាស់ការលើការងារអាទិភាពចម្បងពីរ គឺ ៖ ***ទី១-*** *ការបន្តរក្សានូវស្ថិរភាពនយោបាយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងស្ថានការណ៍ និង* ***ទី២-*** *ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឱ្យបានល្អប្រសើរទប់ស្កាត់អតិផរណា និងការឡើងថ្លៃទំនិញក្នុងទីផ្សារ ។ ជាមួយគ្នានេះ ការជំរុញទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ក៏ដូចជាគោលនយោបាយទាក់ទាញអ្នកវិនិយោគក៏ត្រូវបានអនុវត្តយ៉ាងសកម្ម ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន នឹងផ្តល់ប្រយោជន៍យ៉ាងសំខាន់សម្រាប់ប្រទេសកម្ពុជា ដែលនឹងផ្តល់ឱកាសកាន់តែធំក្នុងការនាំផលិតផលទៅកាន់ប្រទេសចិន ដោយមិនជាប់ពន្ធ ហើយកំណើននៃការនាំចេញនឹងកើនឡើងប្រមាណ ២៥% បន្ថែមទៀត ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង ក៏ត្រូវបានបិទបញ្ចប់ជាផ្លូវការនៅថ្ងៃទី៣ ខែកុម្ភៈ ហើយនៅពេលដែលត្រូវបានដាក់ឲ្យដំណើរការជាផ្លូវការ នឹងជួយជំរុញឲ្យទំហំពាណិជ្ជកម្មនៃប្រទេសទាំងពីរកាន់តែមានការកើនឡើង ។ កម្ពុជាក៏បានគ្រោងធ្វើកិច្ចចរចាស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសផ្សេងៗទៀត ដូចជាអង់គ្លេស អាមេរិក ជប៉ុន ម៉ុងហ្គោលី ឥណ្ឌា និង*

system turning the Covid-19 crisis into an opportunity. Thirdly, to build sustainable and environmental resilience through building and strengthening institutional capacity, increasing human and financial resources, strengthening competitiveness and building a strong local economic base.

In 2021, the Cambodian economy is projected to recover with an expectation to achieve a growth rate of around 4%, bringing the current GDP to around 117,939 billion riels, equivalent to about 29,013 million US dollars, while GDP per capita income is expected to rise to US$ 1,771, compared to US$ 1,683 in 2020. This growth was supported by the recovery of key economic sectors such as agriculture, which is estimated to increase by 1.6% thanks to the growth of the crop sub-sector, livestock sub-sector and fisheries sub-sector. The industry sector was expected to recover at a 4.1% growth rate from negative area owing to lower-than-expected recovery in the garment and construction sub-sectors, while the non-garment manufacturing sub-sector is expected to maintain strong growth. The services sector is projected to grow at 4% thanks to the expected slow recovery in economic activity, especially in tourism and domestic consumption after the Covid-19 crisis.

The average annual inflation rate is estimated to be manageable at 3.1% thanks to expectations of a rise in international oil prices after a sharp decline in 2020. The current account deficit (including diversion) is projected to narrow slightly to 17.3% of GDP based on expectations of a gradual recovery in exports and tourism. Total international reserves are expected to reach US$ 16,981 million guaranteeing eight months imports as the country's imports will recover slightly.

Despite many obstacles and difficulties, we are still optimistic about the development for 2021 because we have many favorable conditions. By 2020, Cambodia, despite suffering from the effects of Covid-19, was able to manage it effectively, with no deaths, no state of emergency, and no partial or national lockdowns. The Royal Government has succeeded in its commitment to maintaining sovereignty over its two major works. Firstly, it has been able to maintain political stability which is the foundation for keeping things under control. Secondly, it has achieved good macroeconomic stability, curbing inflation and rising commodity prices in the market. At the same time, it has been active in promoting international trade relations as well as the policy of attracting investors.

The Cambodia-China Free Trade Agreement will bring significant benefits to Cambodia, with greater opportunities to export products to China duty-free and export growth of about 25%. The Cambodia-South Korea Free Trade Agreement also officially concluded on February 3, and its official launch will help boost the two countries' trade volume. Cambodia also plans to negotiate free trade agreements with other countries such as Britain, the United States,

សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ីថែមទៀត។ កាលពីចុងឆ្នាំ២០២០ កន្លងទៅ ប្រទេសសមាជិកអាស៊ាន ដែលមានទាំងកម្ពុជា ព្រមទាំងប្រទេសចំនួន ៥ទៀត គឺ ចិន ជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី និងណូវែលសេឡង់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចតំបន់គ្រប់ជ្រុងជ្រោយ ហៅកាត់ថា RCEP (regional comprehensive economic partnership) ។ RCEP គឺជាកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី ឈានមុខគេក្នុងពិភពលោក។ សម្រាប់កម្ពុជា ក្រោយពីកិច្ចព្រមព្រៀង RCEP នេះចូលជាធរមាន គិតជាកំណើនប្រចាំឆ្នាំ ការនាំចេញរបស់កម្ពុជានឹងកើនឡើងចំនួន ៧,៣% , ការវិនិយោគកើនឡើង ២៣,៤%, និងផលិតផលក្នុងស្រុកសរុប (ផសស) កើនចំនួនប្រមាណ ២% លើ ផ.ស.ស ដែលមានបច្ចុប្បន្ន ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំច្បាប់វិនិយោគថ្មី ដោយការកែសម្រួលទៅលើ ច្បាប់ចាស់ ដើម្បីឲ្យស្របទៅតាមការវិវត្តន៍របស់សង្គម និងបង្កើនភាពទាក់ទាញកាន់តែខ្លាំងឲ្យវិនិយោគិនចូលមកបណ្ដាក់ទុននៅកម្ពុជា ។ ច្បាប់ស្ដីពីសហគ្រាស-ពាណិជ្ជកម្ម និងច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មក៏កំពុងត្រូវបានធ្វើវិសោធនកម្ម ។ ក្នុងគោលបំណងនេះដែរ ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានប្រកាសដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣ ដោយផ្ដោតលើគោលដៅធំៗចំនួន ៤ រួមមានៈ ការជំរុញពាណិជ្ជកម្មអន្តរជាតិ, ការទាក់ទាញការវិនិយោគទុនផ្ទាល់ពីបរទេស , ការលើកកម្ពស់វិស័យទេសចរណ៍ និងការជំរុញការផ្លាស់ប្ដូរវប្បធម៌ បូករួមទាំងការផ្សព្វផ្សាយពីមុខម្ហូបខ្មែរផងដែរ ។ យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច គឺជាត្រីវិស័យក្នុងការពង្រឹងប្រសិទ្ធភាពការងារ ផ្នែកការទូតសេដ្ឋកិច្ច និងដើម្បីចូលរួមជាវិភាគទាន ពង្រឹងជន្ទល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងលើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ ។ ទន្ទឹមនេះ ការទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាទំនិញជាយុទ្ធសាស្ត្រ នៅខែកុម្ភៈ ដើមឆ្នាំ២០២១ នេះ និងដំណាក់កាលជាបន្តបន្ទាប់ មិនត្រឹមតែបានជួយការពារអាយុជីវិតរបស់ប្រជាជនកម្ពុជា និងកាត់បន្ថយហានិភ័យទាំងឡាយ ដែលបណ្ដាលមកពីជំងឺនេះប៉ុណ្ណោះទេ ប៉ុន្តែវាបានជួយរួមចំណែកយ៉ាងធំធេងក្នុងការស្ដារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមឲ្យកាន់តែមានល្បឿនលឿនថែមទៀត ។

ប៉ុន្តែ យើងក៏នៅតែជួបបញ្ហាប្រឈមមួយចំនួនដូចជា សភាពការណ៍អន្តរជាតិនៅតែបន្តស្ថិតក្នុងសភាពស្មុគស្មាញ និងគ្រោះថ្នាក់ ។ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលនៅតែមានការកើនឡើង ហើយធ្វើឲ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា ។ មួយផ្នែកក៏អាស្រ័យដោយកត្តាខាងក្នុង ដូចជា បញ្ហាតម្លៃ កិច្ចសម្រួលពាណិជ្ជកម្ម សម្រាប់ធុរជន ការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅមានល្បឿនយឺត បរិមាណ និងគុណភាពនៃកម្លាំងពលកម្មជំនាញមិនទាន់អាចឆ្លើយតបតាមតម្រូវការទីផ្សារបាន ។ ប៉ុន្តែបញ្ហាទាំងអស់នេះយើងអាចជម្នះដោះស្រាយបានអាស្រ័យដោយការពង្រឹងការឯកភាពគ្នា គ្រប់ថ្នាក់ គ្រប់ផ្នែក ដោយប្រកាន់ខ្ជាប់នូវស្មារតីនៃការជំរុញការអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែរឹងមាំឡើង ។

ជារួមទោះបីជាសេដ្ឋកិច្ចរបស់កម្ពុជាក្នុងឆ្នាំ២០២០ បានទទួលរងគ្រោះដោយសារឥទ្ធិពលនៃការរាតត្បាតជំងឺកូវីដ-១៩ ប៉ុន្តែផ្អែកលើមូលដ្ឋានសំខាន់ៗដ៏រឹងមាំដែលមានរួចហើយយើងនៅតែមានសុទិដ្ឋិនិយមថាសេដ្ឋកិច្ចកម្ពុជា នឹងបោះជំហានឈានឡើងវិញក្នុងជំហានវិជ្ជមាននៅឆ្នាំ២០២១នេះ៕

Japan, Mongolia, India and the Eurasian Economic Union. In late 2020, ASEAN member countries, including Cambodia, as well as five other countries - China, Japan, South Korea, Australia and New Zealand - signed the Regional Comprehensive Economic Partnership Agreement (RCEP).

RCEP is the world's leading free trade agreement. After RCEP's entry into force, Cambodia's annual exports will increase by 7.3%, investment by 23.4%, and gross domestic product (GDP) will increase about 2% on current GDP. The Royal Government of Cambodia has also prepared a new investment law by amending the old ones to go along with the evolution of society and increase the attractiveness for investors to invest in Cambodia. The Law on Commercial Enterprises and the Law on Commercial Rules and Business Registration are also being amended.

To this end, the Ministry of Foreign Affairs and International Cooperation has announced the implementation of the Economic Diplomacy Strategy 2021-2023, focusing on four main goals - promoting international trade, attracting foreign direct investment, promoting tourism, and promoting cultural change, as well as promoting Khmer cuisine. The Economic Diplomacy Strategy is a compass to strengthen the efficiency of economic diplomacy and to contribute to strengthening economic growth, reducing dependence on foreign aid, and promoting Cambodia's interests in the region and internationally. At the same time, the acquisition of Covid-19 vaccine, a strategic commodity in early February 2021 and subsequent stages, not only saved the lives of the Cambodian people and reduced the risks posed by the disease, but it has greatly contributed to the rapid socio-economic recovery and development.

However, we also face some challenges, such as the international situation continues to be complicated and dangerous. Uncertainty in the global economy continues to increase and affect the Cambodian economy. These developments has partly been so due to internal factors such as price issues, trade facilitation for businesses, slow economic diversification, the quantity and quality of skilled labor has not yet been able to meet market demand. We can, however, overcome all these problems by strengthening the unity at all levels and in all areas, adhering to the spirit of promoting stronger national development.

Overall, although its economy in 2020 was affected by the Covid-19 epidemic, based on the strong existing fundamentals, we remain optimistic that the Cambodian economy will return to a positive step in 2021./.

ត្រូវរឹតបន្តឹងការអនុវត្តវិធានការ ៣ការពារ និង៣កុំ ឲ្យបានជាប់លាប់ល្អ
តាមការណែនាំរបស់ក្រសួងសុខាភិបាល

ពង្រឹងជំនឿទុកចិត្តចំពោះការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាគន្លឹះយុទ្ធសាស្ត្រសម្រាប់កម្ពុជា

វ៉ាក់សាំងស៊ីណូហ្វាម ដែលជាអំណោយរបស់សាធារណរដ្ឋប្រជាមានិតចិនចំនួន ៦០ម៉ឺនដូស ក្នុងចំណោម ១លានដូស ត្រូវបានដឹកជញ្ជូនមកដល់ព្រះរាជាណាចក្រកម្ពុជាកាលពីល្ងាចថ្ងៃទី ៧ ខែ កុម្ភៈ ដោយមាន**សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងឥស្សរជនជាន់ខ្ពស់កម្ពុជាជាច្រើនរូបបានអញ្ជើញចេញទៅទទួលដោយផ្ទាល់នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ វ៉ាក់សាំងការពារជំងឺកូវីដ-១៩ គឺជាវត្ថុដែលមានលក្ខណៈជាគន្លឹះយុទ្ធសាស្ត្រសម្រាប់ប្រទេសកម្ពុជាយើង ពីព្រោះថា វ៉ាក់សាំងនេះបានផ្តល់ប្រយោជន៍ជាសំខាន់គឺ **ទី១-** ជួយការពារអាយុជីវិតប្រជាជនមិនឲ្យស្លាប់ ដោយជំងឺដ៏កាចសាហាវនេះ , កាត់បន្ថយការភ័យព្រួយរបស់ប្រជាជនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងទប់ស្កាត់ការឆ្លងរាលដាល និង**ទី២-** ជួយកម្ពុជាយើងឲ្យអាចគ្រប់គ្រងបានល្អ ដំណើរការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ទាំងក្នុង និងក្រោយដំណាក់កាលនៃជំងឺកូវីដ-១៩ ។

ការផ្តល់អំណោយជាវ៉ាក់សាំងការពារជំងឺកូវីដ-១៩ របស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនមកដល់រដ្ឋាភិបាលកម្ពុជានាពេលនេះ បានឆ្លុះបញ្ចាំងឲ្យឃើញនូវផ្លែផ្កាដ៏មានតម្លៃធំធេងក្នុងទំនាក់ទំនងនៃប្រទេសទាំងពីរកម្ពុជា-ចិន ជាទំនាក់ទំនងមិត្តភាពកិច្ចសហប្រតិបត្តិការ ប្រពៃណី ប្រវត្តិសាស្ត្រ និងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយឈរលើគោលការណ៍ យោគយល់គ្នា គោរពគ្នាទៅវិញទៅមក ផ្តល់ផលប្រយោជន៍ឲ្យគ្នាក្នុងនាមជាអ្នកជិតខាងល្អ មិត្តល្អ បងប្អូនល្អ ជាដៃគូល្អ និងជាមិត្តដែកថែប ។ ជំនួយវ៉ាក់សាំងដែលមានលក្ខណៈជាយុទ្ធសាស្ត្រនេះ មិនត្រឹមតែជួយឲ្យកម្ពុជាដោះស្រាយបានបញ្ហាប្រឈម និងហានិភ័យ ទាក់ទិនទៅនឹងអាយុជីវិតរបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយដល់ការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឡើងវិញ ទាំងក្នុងដំណាក់កាលបច្ចុប្បន្ន និងក្រោយបញ្ចប់វិបត្តិជំងឺកូវីដ-១៩ ។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការសម្រេចចិត្ត ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការទទួលយកវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលជាជំនួយសប្បុរសធម៌របស់ចិននាពេលនេះ គឺដោយសារវ៉ាក់សាំងនេះត្រូវបានប្រទេសជាច្រើនប្រើប្រាស់ជាសាធារណៈប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព ។ ចាប់តាំងពីថ្ងៃទី១០ ខែកុម្ភៈ វ៉ាក់សាំងនេះត្រូវបានប្រើប្រាស់ជាផ្លូវការ ដោយមានថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា និងមន្ត្រីព្រមទាំងប្រជាជន និងកងកម្លាំងប្រដាប់អាវុធ ដែលគ្រប់លក្ខខណ្ឌបានទៅចាក់វ៉ាក់សាំងដើម្បីការពារជំងឺកូវីដ-១៩ នេះលើគោលការណ៍នៃការស្ម័គ្រចិត្តនៅតាមមន្ទីរពេទ្យចំនួន ៤ នៅរាជធានីភ្នំពេញ ។ យុទ្ធនាការចាក់វ៉ាក់សាំង កំពុងតែដំណើរការយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា ។ ដោយឡែក នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រសួងសុខាភិបាលបានអនុញ្ញាតឲ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំង ២ទៀត គឺ Sinovac's COVID-19 ផលិតដោយសាធារណរដ្ឋប្រជាមានិតចិន និងAstra-Zeneca'sCOVID-19របស់ប្រទេសអង់គ្លេស ។វ៉ាក់សាំងទាំង២នេះត្រូវបានប្រើប្រាស់ប្រកបដោយសុវត្ថិភាព នៅក្នុងប្រទេសចិន និងចក្រភពអង់គ្លេស ព្រមទាំងបណ្តាប្រទេសមួយចំនួន ក្នុងលក្ខខណ្ឌនៃការប្រើប្រាស់បន្ទាន់ ។ជាមួយគ្នានេះរាជរដ្ឋាភិបាលក៏កំពុង យកចិត្តទុកដាក់ស្វះស្វែងរកវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ពីប្រភពដទៃទៀត ដើម្បីយកមកប្រើប្រាស់ឲ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងនៅក្នុងប្រទេស ។

ចាប់តាំងពីមានការរីករាលដាលនៃជំងឺកូវីដ-១៩ មកដល់ពេលនេះ កម្ពុជាគ្រប់គ្រងស្ថានការណ៍ជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព ដែលជាលទ្ធផលគិតមកដល់ពេលនេះ កម្ពុជាគ្មានករណីស្លាប់ ឬឈានដល់ការដាក់ប្រទេសក្នុងគ្រាអាសន្ន ព្រមទាំងមិនមានការបិទជាតំបន់ ឬបិទប្រទេសទាំងមូលនោះឡើយ ។ ប៉ុន្តែទោះបីជាមានវ៉ាក់សាំងការពារហើយក៏ដោយ ក៏មិនមែនមាន ន័យថា យើងទាំងអស់គ្នានឹងអាចវិលត្រលប់ទៅប្រក្រតីភាពវិញ ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះបានឡើយ ។ យើងក៏មិនត្រូវព្រងើយកន្តើយ ឈប់អើពើ ឈប់ប្រុងប្រយ័ត្ន និងឈប់ខ្វល់ខ្វាយភ័យព្រួយជាមួយជំងឺនេះដែរ ។ កន្លងមកនេះ ការឆ្លងរាតត្បាតនៃជំងឺ កូវីដ១៩ ចូលទៅក្នុងសហគមន៍នៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម ដែលមានព្រំដែនជាប់ប្រទេសកម្ពុជា នៅតែបង្កជាហានិភ័យខ្ពស់សម្រាប់យើង ។មួយរយៈកន្លងមកនេះយើងទប់ស្កាត់បានជោគជ័យនូវការចម្លងពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមរយៈបងប្អូនពលករខ្មែរយើង និងការពារមិនឲ្យមានការឆ្លងរាលដាលចូលផ្ទៃក្នុងប្រទេស។ រាជរដ្ឋាភិបាលក៏បានដាក់បទបញ្ជាឲ្យបណ្តាអាជ្ញាធរមានសមត្ថកិច្ចទាំងឡាយ នៅបណ្តាខេត្តប៉ែកខាងកើត ដែលមានព្រំដែនជាប់ប្រទេសវៀតណាម ឲ្យប្រកាន់យកវិធានការតឹងរ៉ឹង ម៉ឺងម៉ាត់ និងម៉ត់ចត់បំផុត ក្នុងការទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ ចូលមកក្នុង ប្រទេសកម្ពុជា ។

ក្នុងស្មារតីនេះ ប្រជាជនយើងទាំងអស់គ្នាទោះជាអ្នកដែលបានទទួលការចាក់វ៉ាក់សាំងហើយក្តី ឬក៏មិនទាន់ទទួលបានការចាក់វ៉ាក់សាំងក្តី ក៏ត្រូវតែខិតខំអនុវត្តនូវវិធានការរបស់ក្រសួងសុខាភិបាល និងអនុសាសន៍របស់**សម្តេចតេជោ ហ៊ុន សែន** រួមគ្នាការពារ នឹងប្រយុទ្ធជាមួយជំងឺកូវីដ១៩ដោយអនុវត្តតាមគោលការណ៍ □**៣កុំ**□ គឺកុំទៅកន្លែងដែលមានមនុស្សកុះករ កុំទៅកន្លែងបិទជិត និងកុំអោបរឹតគ្នា និង □**៣ការពារ**□ គឺត្រូវពាក់ម៉ាស់ លាងដៃឲ្យស្អាត និងរក្សាគំលាតយ៉ាងតិចឲ្យបាន ១ម៉ែត្រកន្លះ ។អនុវត្តបានតាមវិធានការទាំងអស់នេះ យើងអាចការពារបាននូវសុខភាព និងសុវត្ថិភាពរបស់ខ្លួនយើងម្នាក់ៗ ក៏ដូចជាសុខមាលភាពរបស់ក្រុមគ្រួសារ របស់សហគមន៍ និងរបស់សង្គមជាតិយើងទាំងមូល ៕

សម្ដេចតេជោ ហ៊ុន សែន ៖ ជំនួយវ៉ាក់សាំងការពារជំងឺកូវីដ១៩ ជាសក្ខីភាពថ្មី ឆ្លុះបញ្ចាំងអំពីចំណងមិត្តភាពដែកថែបកម្ពុជា-ចិន

❋ កម្ពុជាមិនធ្វើអត្ថាធិប្បាយលើកិច្ចការផ្ទៃក្នុងប្រទេសអាស៊ានទាំងអស់

សម្ដេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន

❋ នៅព្រឹកថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំការមន។ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតចម្ការមន មានសមត្ថភាពផលិតទឹកស្អាត ៥២.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលពីមុនអាចផលិតទឹកស្អាតបានត្រឹមតែ ១២.០០០ម៉ែត្រគូបក្នុងមួយថ្ងៃប៉ុណ្ណោះ។ **សម្ដេចតេជោ ហ៊ុន សែន** បានសម្ដែងនូវមោទនភាពចំពោះសមិទ្ធផលទាំងនេះ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការបម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ និងសង្គមជាតិ។ **សម្ដេចតេជោ ហ៊ុន សែន** ថ្លែងថា តម្រូវការទឹកក្នុងទីក្រុងភ្នំពេញបច្ចុប្បន្នត្រូវការទឹកជាង៧០ម៉ឺនម៉ែត្រគូប ខណៈការផលិតបានត្រឹមជាង៦០ម៉ឺនម៉ែត្រគូប ខ្វះប្រមាណ ១៥ម៉ឺនម៉ែត្រគូប។ ប្រជាពលរដ្ឋ៤ម៉ឺនគ្រួសារខ្វះទឹកប្រើប្រាស់។ តម្រូវការទឹកក្នុងរាជធានីភ្នំពេញ គឺកើនឡើងរាល់ថ្ងៃ ដូច្នេះត្រូវតែប្រឹងប្រែងក្នុងការអភិវឌ្ឍសមត្ថភាពផលិត និងផ្គត់ផ្គង់ទឹកស្អាត។ ស្ថាប័នរដ្ឋទាំងអស់ ត្រូវយកចិត្តទុកដាក់ក្នុងការកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនី និងទឹក។ សម្ដេចតេជោថ្លែងអំណរគុណចំពោះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងក្រុមហ៊ុនរបស់ប្រទេសបារាំង ដែលបានចូលរួមក្នុងការអភិវឌ្ឍវិស័យទឹកស្អាតនេះ។ សម្ដេចតេជោថ្លែងថា "ខ្ញុំសុំប្រកាសក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមប្រកាសគាំទ្រពាក្យស្លោកដែលស្នើឡើងដោយឯកឧត្តម **ចម ប្រសិទ្ធ** ដែលលើកឡើងថា "**ទឹកស្អាតសម្រាប់ទាំងអស់គ្នា**" ការកំណត់ទិសស្លោកនេះ ធ្វើឲ្យយើងទាំងអស់គ្នាគិតគូរដោយមធ្យ័តបំផុតទៅលើសកម្មភាពទាំងឡាយដើម្បីប្រើប្រាស់ទឹកស្អាតសម្រាប់ទាំងអស់គ្នា"។ នៅក្នុងគម្រោងពង្រីកសមត្ថភាពរោងចក្រនេះ រួមមានការពង្រីកបណ្ដាញបំពង់ទឹកស្អាតប្រវែង ៥៨០គីឡូម៉ែត្រ ក្នុងនោះប្រជាពលរដ្ឋប្រមាណជា ២៨០.០០០នាក់ បានទទួលទឹកស្អាតប្រើប្រាស់ផ្ទាល់ពីបណ្ដាញទឹករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។ ជាពិសេសប្រជាពលរដ្ឋចំណូលទាប រស់នៅតាមសហគមន៍ ស្ថិតនៅតំបន់ជាយរាជធានីភ្នំពេញបែកខាងត្បូង។ គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង គឺជាគម្រោងទី២ របស់ផែនការមេដំណាក់កាលទី៣ នៅពេលសិក្សាវបាយការណ៍សមិទ្ធិលទ្ធភាពនៅឆ្នាំ២០១៧ បានកំណត់ទីតាំងរបស់គម្រោងស្ថិតនៅសង្កាត់បាក់ខែងមានចម្ងាយ១០គីឡូម៉ែត្រខាងជើងស្ពានមិត្តភាពកម្ពុជា-ជប៉ុន (ស្ពានជ្រោយចង្វារ)។ គម្រោងសាងសង់ស្ថិតនៅសង្កាត់បាក់ខែង លើផ្ទៃដីទំហំធំ និងផ្លូវទាំងសងខាងមានទំហំធំទូលាយងាយស្រួលក្នុងការដំឡើងបំពង់មេដែលមានអង្កត់ផ្ចិតធំ ដើម្បីដាក់ឆ្លងកាត់តាមបាតទន្លេសាប រួចតភ្ជាប់មកតំបន់មួយចំនួននៅរាជធានីភ្នំពេញ។ គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង គឺជាគម្រោងសាងសង់ដ៏ធំមួយដែលមិនធ្លាប់មានពីមុនមកនៅកម្ពុជាមានសមត្ថភាពផលិតទឹកស្អាត ៤០០.០០០ម៉ែត្រគូបក្នុងថ្ងៃ(សម្រាប់ជំហានទី១ និងជំហានទី២)។ ដំណើរការសាងសង់រោងចក្រនេះ នឹងអនុវត្តជាពីរជំហានស្របគ្នាតែម្ដង និងគ្រោងដាក់ដំណើរការសាកល្បងក្នុងសមត្ថភាពផលិតទឹកស្អាតពាក់កណ្ដាល (ជិត២០ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ) នៅត្រីមាសទី១ ឆ្នាំ២០២៣ ហើយនឹងដាក់ដំណើរការពេញសមត្ថភាពទាំងពីរជំហាន (ជិត៤០ម៉ឺនម៉ែត្រគូបក្នុងមួយថ្ងៃ) នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងអំណរព្រះគុណព្រះមហាក្សត្រ ព្រះមហាក្សត្រី ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់ ដែលបានផ្ដល់ព្រះរាជអំណោយ និងជំនួយជួយទិញវ៉ាក់សាំង បានបង្ហាញពីស្មារតីនៃសាមគ្គីភាពនៅក្នុងសង្គមកម្ពុជា។ **សម្ដេចតេជោ ហ៊ុន សែន** បានបញ្ជាក់ពីប្រភពវ៉ាក់សាំង ដែលកម្ពុជានឹងទទួលបានប្រមាណ ២០លានដូស។ ក្នុងនោះ ទទួលបានជំនួយពីចិន ១លានដូស ដែលនឹងមកដល់នៅក្នុងខែកុម្ភៈ ចំនួន ៦០ម៉ឺនដូស ទទួលពីកូវ៉ាក់ ដែលជារបស់អង្គការសុខភាពពិភពលោក ៧លានដូស និងទិញតាមកូវ៉ាក់១លានដូស ព្រមទាំងទទួលបានតាមរយៈជំនួយពីអូស្ត្រាលី៣លានដូស។ ក្រៅពីនោះកម្ពុជាពិចារណាទិញពីប្រទេសអង់គ្លេសផងដែរ ។ សម្ដេចតេជោបញ្ជាក់ទៀតថា បើវ៉ាក់សាំងមួយដូសតម្លៃចន្លោះពី៤ទៅ៥ដុល្លារនោះ គឺព្រះរាជអំណោយព្រះមហាក្សត្រ និងសម្ដេចម៉ែ ព្រមទាំងការចូលរួមរបស់ប្រជាពលរដ្ឋខ្មែរជាង ៥៧លានដុល្លារ គឺគ្រប់គ្រាន់ហើយ។ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានទទូចឲ្យអ្នកដំណើរចូលមកកម្ពុជា ត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃ ដោយមិនអាចបន្ធូរបន្ថយ និងខកខានបានឡើយ ដើម្បីទប់ស្កាត់ ការរីករាលដាល ជំងឺកូវីដ១៩ ចូលក្នុងសហគមន៍កម្ពុជាជាថ្មីម្ដងទៀត។ សម្ដេចតេជោក៏បានអំពាវនាវដល់ពលករខ្មែរ មកពីប្រទេសថៃក៏ដូចជាអ្នកដំណើរមកពីប្រទេសផ្សេងៗ ដែលចូលមកកម្ពុជា ត្រូវតែត្រួតពិនិត្យសុខភាព ហើយធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ជាដាច់ខាត

សម្ដេចតេជោ ហ៊ុន សែន អញ្ជើញទទួលវ៉ាក់សាំងការពារជំងឺកូវីដ១៩ ដែលជាជំនួយរបស់រដ្ឋាភិបាលចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

ដោយមិនអាចកាត់បន្ថយថ្លៃ ធ្វើចត្តាឡីស័កនោះទេ ។

ទាក់ទិនទៅនឹងព្រឹត្តិការណ៍នៅប្រទេសមីយ៉ាន់ម៉ា សម្ដេចតេជោ **ហ៊ុន សែន** បានថ្លែងបញ្ជាក់ថា នោះជាកិច្ចការផ្ទៃក្នុងដោយកម្ពុជាមិនធ្វើការអធិប្បាយទៅលើកិច្ចការផ្ទៃក្នុងរបស់ប្រទេសណាទាំងអស់ នៅក្នុងអាស៊ាន ។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា តំណាក់ប្រេងដំបូងរបស់កម្ពុជា ដែលទទួលបាននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ មានអណ្តូងទី១ ដំណើរការបានរយៈពេល ៣៣ថ្ងៃ ផលិតបាន ៤០.៧៨៨បារ៉ែល ដោយក្នុងមួយថ្ងៃ បូមបានប្រមាណ១.២៣៦បារ៉ែល ។ តាមការវាយតម្លៃកម្ពុជាអាចចម្រាញ់ប្រេងបានចន្លោះពី៧.០០០ ទៅ៧.៥០០ បារ៉ែលប៉ុណ្ណោះក្នុងមួយថ្ងៃ ដែលនេះជាចំនួនមួយតិចតួចនៅឡើយ តែជាការបោះជំហានមួយល្អលើវិស័យប្រេងនៅកម្ពុជា ។ ដូច្នេះប្រេងមិនទាន់អាចជះឥទ្ធិពលដល់សេដ្ឋកិច្ចបានទេនៅក្នុងដំណាក់កាលទី១នេះ ទោះបីជាកម្ពុជា បានទទួលតំណាក់ប្រេងលើកដំបូងកាលពីចុងឆ្នាំ២០២០ក៏ដោយ ប៉ុន្តែវាជាការចាប់ផ្តើមមួយដ៏ល្អនៃដំណើរការឧស្សាហកម្មប្រេង និងឧស្ម័ននៅកម្ពុជា ។

✵នៅរសៀលថ្ងៃទី០៧ខែកុម្ភៈឆ្នាំ២០២១ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលវ៉ាក់សាំងការពារជំងឺកូវីដ១៩ ដែលជាជំនួយរបស់រដ្ឋាភិបាលចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។ វ៉ាក់សាំងដែលបានបញ្ជូនមកដល់កម្ពុជានាពេលនេះ មានចំនួន ៦០ម៉ឺនដូសក្នុងជំហានដំបូង ដោយក្នុងនោះចំនួន៣០ម៉ឺនដូសសម្រាប់ក្រសួងសុខាភិបាលនិង៣០ម៉ឺនដូសទៀត សម្រាប់ផ្នែកយោធា ។

សម្ដេចតេជោ ហ៊ុន សែន បានសម្ដែងសេចក្តីរីករាយឥតឧបមា ដោយបានមកចូលរួមដោយផ្ទាល់ក្នុងឋានៈជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងពិធីប្រគល់-ទទួលវ៉ាក់សាំងកូវីដ-១៩ ចំនួន ៦០ ម៉ឺនដូស ជាជំហានទី១ក្នុងចំណោម១លានដូសដែលជាជំនួយដ៏សប្បុរសពីសំណាក់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន តាមរយៈក្រសួងការពារជាតិចិនជូនដល់ប្រជាជនកម្ពុជា ។ សម្ដេចតេជោបានគូសបញ្ជាក់ថា ជំនួយវ៉ាក់សាំងនេះ គឺពិតជាសក្ខីភាពថ្មីដ៏សំខាន់មួយទៀត ដែលឆ្លុះបញ្ចាំងអំពីចំណងមិត្តភាពដែកថែប និងកិច្ចសហប្រតិបត្តិការដ៏រឹងមាំរវាងប្រទេស និងប្រជាជនទាំងពីរ កម្ពុជា-ចិន នៅក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងការកសាងសហគមន៍វាសនារួមគ្នា ។ សុភាសិតខ្មែរពោលថា «**មិត្តល្អជួយគ្នាក្នុងគ្រាក្រ**» ។ **សម្ដេចតេជោ ហ៊ុន សែន** ថ្លែងថា វ៉ាក់សាំងការពារជំងឺ កូវីដ-១៩ គឺជាតម្រូវការជាយុទ្ធសាស្ត្រដ៏សំខាន់មួយរបស់កម្ពុជា នៅក្នុងការប្រយុទ្ធប្រឆាំង និងការឈានទៅយកឈ្នះលើជំងឺកូវីដ-១៩ ។ ទោះបីវ៉ាក់សាំងមិនមែនជាដំណោះស្រាយ មាសតែមួយគត់សម្រាប់យកឈ្នះលើជំងឺកូវីដ-១៩ ដែលចាំបាច់ត្រូវអនុវត្តរួមគ្នាជាមួយនឹងវិធានការបង្ការ និងការពារដទៃទៀតក្តី ប៉ុន្តែវ៉ាក់សាំង គឺជាដំណោះស្រាយគន្លឹះជាយុទ្ធសាស្ត្រមួយ សម្រាប់ធានាការពារអាយុជីវិតប្រជាជននៅក្នុងពេលចំពោះមុខ និងសម្រាប់លើកកម្ពស់សុខភាពសាធារណៈក្នុងរយៈពេលវែងទៅមុខ ពិសេសសម្រាប់ការធានាឲ្យសកម្មភាពសង្គម-សេដ្ឋកិច្ចអាចដំណើរការពេញលេញឡើងវិញ ដែលនឹងជំរុញលើកស្ទួយនូវការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច និងការកែលម្អជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេស ។ សម្ដេចតេជោបន្តថា រាជរដ្ឋាភិបាលកម្ពុជា ដោយមានក្រសួងសុខាភិបាលជាសេនាធិការដឹកនាំសម្របសម្រួលខាងបច្ចេកទេស បានសហការជាមួយនឹងដៃគូពាក់ព័ន្ធ រៀបចំរួចស្រេចបាច់នូវយុទ្ធសាស្ត្រវ៉ាក់សាំងកូវីដ-១៩ ដែលរួមបញ្ចូលនូវផែនការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងគោលការណ៍ណែនាំប្រតិបត្តិសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ព្រមទាំងយន្តការចាំបាច់សម្រាប់អនុវត្តកិច្ចការនេះ ។ **សម្ដេចតេជោ ហ៊ុន សែន** បានថ្លែងថា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូលពិតជាមានការដឹងគុណដ៏ជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនចិន ដែលបានផ្តល់នូវជំនួយវ៉ាក់សាំងចំនួន ៦០ ម៉ឺនដូស ជាជំហានទី ១ ក្នុងចំណោម ១ លានដូស តាមរយៈក្រសួងការពារជាតិចិនជូនដល់កងទ័ព និងប្រជាជនកម្ពុជានាពេលនេះ ។ សម្ដេចតេជោបានគូសបញ្ជាក់ថា វ៉ាក់សាំង Sinopharm របស់មិត្តចិន ដែលត្រូវបានផ្តល់មកកម្ពុជា នេះ គឺជាប្រភេទវ៉ាក់សាំងដែលត្រូវបានទទួលស្គាល់ថាជាវ៉ាក់សាំងមួយដែលមានសុវត្ថិភាព និង ប្រសិទ្ធភាព និងត្រូវបានបញ្ជាទិញ ព្រមទាំងអនុម័ត ឲ្យប្រើប្រាស់ដោយប្រទេសជាច្រើន នៅក្នុងតំបន់ និងលើសកលលោក ។ ជាមួយនឹងវ៉ាក់សាំងនេះ មិត្តចិនក៏បានផ្តល់ភ្ជាប់ មកផងដែរ នូវជំនួយបច្ចេកទេសសម្រាប់គ្រប់គ្រងការបែងចែក ការចាក់វ៉ាក់សាំង និងការតាមដានត្រួតពិនិត្យ សុវត្ថិភាព និងប្រសិទ្ធភាពនៃវ៉ាក់សាំង ។ រាជរដ្ឋាភិបាលកម្ពុជារំពឹងថា បន្ទាប់ពីជំនួយជាកញ្ចប់ទាំងវ៉ាក់សាំង ទាំងជំនួយបច្ចេកទេសជាជំហានទីមួយនេះ មិត្តចិននឹងបន្តរួមចំណែកយ៉ាងសកម្មជាមួយនឹងដៃគូសំខាន់ៗទាំងឡាយរបស់យើងរួមមានមជ្ឈមណ្ឌលកូវ៉ាក់ (COVAX), អូស្ត្រាលី ព្រមទាំងដៃគូ និងតួអង្គពាក់ព័ន្ធផ្សេងទៀត ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់របស់កម្ពុជា ដើម្បីសម្រេចបាននូវផែនការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ។

សម្ដេចតេជោ ហ៊ុន សែន បានថ្លែងឲ្យដឹងថា ចំនួនវ៉ាក់សាំងកូវីដ-១៩ ដែលផលិតចេញនៅលើពិភពលោកពេលនេះមានចំនួនតិចជាងតម្រូវការ ។ ប្រទេសជាច្រើនមានលទ្ធភាពទិញវ៉ាក់សាំងកូវីដ១៩ ប៉ុន្តែពុំមានវ៉ាក់សាំងដើម្បីឱ្យពួកគេទិញឡើយ ។ សម្ដេចតេជោនាយករដ្ឋមន្ត្រីបានបង្ហាញមោទនភាព ដែលកម្ពុជាបានទទួលវ៉ាក់សាំងកូវីដ១៩ នាពេលនេះដោយសារតែកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយមិត្តចិននារយៈពេលកន្លងមក ។ សម្ដេចតេជោបានបញ្ជាក់ថា មូលហេតុដែលសម្ដេចសម្រេចមិនចាក់វ៉ាក់សាំងកូវីដ១៩ តាមផែនការនោះ ដោយសារតែទទួលបានលិខិតបញ្ជាក់

ផ្លូវការពីស្ថានទូតចិនថា វ៉ាក់សាំងមានប្រសិទ្ធភាពលើអាយុ១៨ ដល់ ៥៩ឆ្នាំ។ សម្ដេចតេជោក៏បានលើកឡើងអំពីគម្រោងចរចាដើម្បីទិញវ៉ាក់សាំងកូវីដ១៩ ពីប្រទេសថៃ ដែលនឹងផលិតបាននៅឆ្នាំនេះ និងពិចារណាក្នុងការស្វែងរកវ៉ាក់សាំងកូវីដ-១៩ ពីប្រទេសរុស្ស៊ីផងដែរ។ សម្ដេចតេជោមានបំណងផ្ដល់ជូនប្រជាពលរដ្ឋចំនួន៨០% នៃប្រជាពលរដ្ឋសរុប ដែលស្មើនឹងចំនួន១៣លាននាក់ ត្រូវការវ៉ាក់សាំងប្រមាណ ២៦លានដូស។ តែបន្ទាប់ពីឆ្លងកាត់ការពិភាក្សាជាប់ជាប្រចាំជាមួយគណៈកម្មការកូវ៉ាក់គឺខាងកូវ៉ាក់បានឲ្យយោបល់ថា គួរផ្ដល់ត្រឹម ៦០% ទៅ ៧០% ឬសម្រាប់តែ១០លាននាក់បានហើយ តែសម្ដេចនៅតែចង់ផ្ដល់ជូនប្រជាពលរដ្ឋឲ្យបានចំនួន៨០%នៃប្រជាពលរដ្ឋសរុប។តាមការប្រមើលមើលរបស់សម្ដេចតេជោ ប្រភពច្បាស់លាស់នៃវ៉ាក់សាំងគឺចិន ដែលនៅតែជាប្រភពយុទ្ធសាស្ត្រ ដោយសារចិនគឺមានការងាយស្រួលដឹកជញ្ជូន និងសីតុណ្ហភាពក៏ងាយស្រួលក្នុងការរក្សាទុក(ដែលចន្លោះតែពី ៦ ដល់ ៨ អង្សា)។ ប្រភពមួយទៀតគឺគណៈកម្មការកូវ៉ាក់របស់អង្គការសុខភាពពិភពលោកនឹងផ្ដល់វ៉ាក់សាំងសម្រាប់ចំនួនប្រជាជន ២០% នៃប្រជាជនសរុប ស្មើនឹង ៣,៥ លាននាក់ឬស្មើនឹង៧លានដូសដែលនេះជាច្រកទ្វារមួយទៀតហើយតាមព័ត៌មាន គឺកូវ៉ាក់មានវ៉ាក់សាំងក្នុងដៃរួចហើយ។ ប្រភពមួយផ្នែកទៀតគឺទទួលបានពីប្រទេសអូស្ត្រាលី ដែលមាន៣ លានដូស ដូច្នេះតាមទិន្នន័យវ៉ាក់សាំងពីប្រភពទាំង ៣នេះ កម្ពុជានឹងទទួលបានវ៉ាក់សាំងសរុប១១លានដូស (ដែលនៅថ្ងៃនេះគឺយើងទទួលបាន៦០ម៉ឺនដូស ពីមិត្តចិន) ។ ដូច្នេះ បើតម្រូវការ២០លានដូស សម្រាប់១០លាននាក់ គឺយើងត្រូវការ៩លានដូសបន្ថែម តែបើយើងប្រើសម្រាប់ ១៣ លាននាក់ គឺយើងនៅខ្វះ១៥លានដូស។ កម្ពុជាក៏បានស្នើទៅមិត្តឥណ្ឌា ហើយមិត្តឥណ្ឌាអាចផ្ដល់ជាការលក់ ១០ម៉ឺនដូស (ដែលវ៉ាក់សាំងនេះផលិតតាមបច្ចេកទេសអង់គ្លេសដែលមានឈ្មោះថា អេស្ត្រាសេនីកាល) ដូច្នេះសម្ដេចតេជោ សូមឲ្យរដ្ឋមន្ត្រី ធ្វើការចរចា ស្នើទិញពីឥណ្ឌា ១០ លានដូស ។ប្រភពមួយទៀត គឺយើងអាចទិញវ៉ាក់សាំងពីថៃ(អេស្ត្រាសេនីកាល) ដែលប្រទេសថៃនឹងផលិតនៅខែឧសភាខាងមុខនេះ ចំពោះតម្លៃវ៉ាក់សាំងនេះគឺ ប្រមាណតែ $៤ ក្នុងមួយដូស ហេតុនេះ យើងចំណាយតែ ៤០លានដុល្លារ សម្រាប់១០លានដូស ដែលចំនួននេះគឺយើងអាចប្រើថវិកាសប្បុរសជនបាន។

ក្នុងឱកាសនោះ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានក្រើនរំលឹកដល់គ្រប់ក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ទាំងអស់ឲ្យបន្តបង្កើន និងពង្រឹងកិច្ចប្រឹងប្រែងអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីការពារសុវត្ថិភាព និងសុខមាលភាពរបស់ប្រជាជនយើងនៅគ្រប់ទិសទី ។ សម្ដេចតេជោក៏បានអំពាវនាវដល់ប្រជាជនកម្ពុជាគ្រប់រូប សូមគោរពនិងប្រកាន់ខ្ជាប់នូវវិធានការសុខាភិបាល ដើម្បីការពារសុខភាព និងសុវត្ថិភាព ផ្ទាល់ខ្លួន ក៏ដូចជាសុខមាលភាពរបស់ក្រុមគ្រួសារ របស់សហគមន៍ និងរបស់សង្គមជាតិយើងទាំងមូល។

❈ នៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្លែងសារពិសេសទៅកាន់បងប្អូនប្រជាពលរដ្ឋទូទាំងប្រទេស ពាក់ព័ន្ធស្ថានភាពឆ្លងជំងឺកូវីដ១៩ថ្មី ដែលជាករណីឆ្លងសហគមន៍២០កុម្ភៈ ។

***សម្ដេចតេជោ ហ៊ុន សែន** អញ្ជើញ ថ្លែងសារពិសេសទៅកាន់ប្រជាពលរដ្ឋ ពាក់ព័ន្ធស្ថានភាពឆ្លងជំងឺកូវីដ១៩ថ្មី ដែលជាព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ*

សម្ដេចតេជោថ្លែងថា ក្រសួងសុខាភិបាលបានរកឃើញករណីឆ្លងចូលសហគមន៍រហូតដល់ចំនួន ៣២ករណី។ សម្ដេចតេជោចាត់ទុកថា ការរកឃើញកូវីដ១៩ថ្មីនេះ ជាព្រឹត្តិការណ៍អាក្រក់ និងធ្ងន់ធ្ងរ ដែលយើងត្រូវតែបង្កើនការការពារបន្ថែមទៀត។

ពាក់ព័ន្ធទៅនឹងការឆ្លងចូលសហគមន៍ ២០កុម្ភៈនេះ **សម្ដេចតេជោ ហ៊ុន សែន** ចេញបទបញ្ជា និងអំពាវនាវឱ្យពលរដ្ឋខ្មែរចំនួន៦ចំណុចដូចតទៅ៖

១-ស្នើសុំការយោគយល់ពីអ្នកធុរកិច្ច និងការស្នាក់ការនៅរបស់ពលរដ្ឋដែលតម្រូវឱ្យមានការបិទអគារ ក្លឹបកម្សាន្តN8 និងតំបន់មួយចំនួនដែលផ្ទុះករណីកូវីដ១៩ ជាចាំបាច់ ដោយមិនអនុញ្ញាតឲ្យចេញ-ចូល លើកលែងតែអ្នកដែលជាម្ចាស់ផ្ទះក្នុងតំបន់នោះ គឺឲ្យចូល តែមិនអនុញ្ញាតឲ្យចេញ **២**-បន្តយកសំណាកធ្វើតេស្តសម្រាប់អ្នកនៅក្នុងតំបន់មានផ្ទុះកូវីដ១៩ បន្ទាប់ពីធ្វើតេស្តហើយត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃ ដែលចំនួននៃការធ្វើតេស្តអាចនឹងមានចំនួនច្រើន **៣**-អាជ្ញាធរត្រូវបន្តស្វែងរកអ្នកពាក់ព័ន្ធនឹងក្លឹបN8 ទោះទៅដល់ទីណាក៏ដោយ ដើម្បីស្វែងរកមកធ្វើតេស្ត នឹងការធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវ **៤**-ត្រូវធ្វើចត្តាឡីស័កសម្រាប់អ្នកដែលមានការពាក់ព័ន្ធទាំងអស់ និងត្រូវយកសំណាករបស់ពួកគាត់មកធ្វើតេស្តផងដែរ **៥**-អំពាវនាវដល់អ្នកពាក់ព័ន្ធនឹងក្លឹប N8 ទាំងអស់ និងពាក់ព័ន្ធនឹងអ្នកមានជំងឺកូវីដ១៩ ទាំង ៣២នាក់នេះ ម្ចាស់ការមកឱ្យពិនិត្យសំណាកជាចាំបាច់បំផុត **៦**- ពលរដ្ឋនៅភ្នំពេញ និងតំបន់ដទៃទៀត ត្រូវបង្កើនការប្រុងប្រយ័ត្ន ហើយរឹតបន្តឹងក្នុងការអនុវត្តវិធានការ៣ការពារ និង៣កុំ ឲ្យបានជាប់លាប់ល្អតាមការណែនាំរបស់ក្រសួងសុខាភិបាល។

សម្ដេចតេជោ ហ៊ុន សែន ជំរុញឲ្យពាក់ម៉ាស់នៅកន្លែងសាធារណៈទាំងអស់ ហើយរក្សាគម្លាតសុវត្ថិភាពឲ្យបានល្អប្រសើរ ហើយបើប្រជាពលរដ្ឋ គ្មានការចាំបាច់ សូមកុំចេញពីផ្ទះ។ សម្ដេចតេជោផ្ដាំផ្ញើកុំឱ្យពលករខ្មែរត្រឡប់ពីប្រទេសថៃដើម្បីមកចូលរួមបុណ្យចូលឆ្នាំខ្មែរ នៅខែមេសាខាងមុខនេះព្រោះនឹងត្រូវជាប់ធ្វើចត្តាឡីស័កមិនបានចូលឆ្នាំនឹងគេទេ។

សម្ដេចតេជោ ហ៊ុន សែន សង្ឃឹមថា ព្រឹត្តិការណ៍ឆ្លងក្នុងសហគមន៍ ២០កុម្ភៈ នឹងត្រូវបិទបញ្ចប់នៅអំឡុងពេល១ខែ នៅពេលប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធទាំងអស់ ចូលរួមសហការ និងអនុវត្តវិធានការទាំងអស់គ្នាដោយយកចិត្តទុកដាក់៕

សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ក្រើនរំលឹកយុវជន ជំនាន់ក្រោយឲ្យខិតខំរៀនសូត្រ ដើម្បីអនាគតរុងរឿង

***សម្ដេចចក្រី ហេង សំរិន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះបឋមសិលាកសាងអគារសិក្សាថ្មី ១ ខ្នង កម្ពស់ ២ជាន់ មាន ១២បន្ទប់ នៅវិទ្យាល័យសម្ដេចចក្រី **ហេង សំរិន** អន្លង់ជ្រៃ*

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះបឋមសិលាកសាងអាគារសិក្សាថ្មី ១ ខ្នង កម្ពស់ ២ជាន់ មាន ១២បន្ទប់ នៅវិទ្យាល័យសម្ដេចចក្រី ហេង សំរិន អន្លង់ជ្រៃ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចផ្ទាល់ និង**សម្ដេចធម្មវិសុទ្ធវង្សា-សៅទី ហេងសំរិន** ។

សម្ដេចពញាចក្រីបានមានប្រសាសន៍ថា ការយកចិត្តទុកដាក់ចំពោះការអប់រំរៀនសូត្ររបស់កុមារ មិនមែនជាកិច្ចការថ្មីដែលយើងទើបចាប់ផ្ដើមនោះទេ។ រាជរដ្ឋាភិបាលបានធ្វើកិច្ចការនេះ ចាប់តាំងពីក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ មកម្ល៉េះ។ កុមារយើងត្រូវបានការពារ ការជួយឧបត្ថម្ភគាំទ្រ ការចិញ្ចឹមបីបាច់ថែរក្សា ការផ្ដល់អាហារូបត្ថម្ភ ការអប់រំរៀនសូត្រ ត្រូវបានលើកតម្កើងជាបន្តបន្ទាប់។ ក្នុងរយៈពេលជាង៤០ ឆ្នាំកន្លងមកនេះ យើងបានគិតគូរយកចិត្តទុកដាក់ខ្ពស់ចំពោះការសិក្សាដោយបានបង្កលក្ខណៈធ្វើឱ្យកុមារនិងយុវជនជំនាន់ក្រោយៗនេះ ទទួលបានការសិក្សាពេញលេញរហូតទទួលបានសញ្ញាបត្របរិញ្ញាបត្រ និងក្រោយឧត្តមសិក្សារាប់សិបពាន់នាក់ ក្នុងមួយឆ្នាំៗ ព្រមទាំងមានឱកាសធ្វើការងារ និងមានមុខរបរដូចបណ្ដាប្រជាជាតិក្នុងតំបន់ ហើយបានរួមចំណែកដល់កំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងការកាត់បន្ថយអត្រានៃភាពក្រីក្ររបស់ប្រជាជនយើង។ សម្ដេចចក្រីបានក្រើនរំលឹកថា ក្មួយៗគឺជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេនក្នុងការគ្រប់គ្រងនិងអភិវឌ្ឍប្រទេសជាតិយើងឱ្យកាន់តែប្រសើរថែមទៀត។ ក្នុងន័យនេះក្មួយៗត្រូវខិតខំប្រឹងប្រែងរៀនសូត្រឱ្យខ្ពង់ខ្ពស់ហើយក្លាយជាយុវជនគំរូ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទាំងចំណេះដឹង និងចរិយាសម្បត្តិ ដែលនឹងក្លាយជាអ្នកដឹកនាំនៅក្នុងពេលអនាគតទាំងការគ្រប់គ្រងស្ថាប័ន ក៏ដូចជាមេគ្រួសារផងដែរ។

ចំពោះបញ្ហាការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ **សម្ដេចអគ្គ-មហាពញាចក្រី ហេង សំរិន** បានលើកឡើងថា ប្រទេសកម្ពុជាយើងមានភ័ព្វសំណាងជាងប្រទេសនានានៅក្នុងតំបន់ និងសកលលោក ជាពិសេសប្រទេសជឿនលឿនដែលមកដល់ពេលនេះ សាលារៀនភាគច្រើន នៅមិនទាន់បើកដំណើរការឱ្យសិស្សមករៀនដោយផ្ទាល់នៅសាលាដូចក្មួយៗនៅទីនេះឡើយ ។ ជំងឺនេះបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសេដ្ឋកិច្ច និងសង្គម ជាពិសេសលើសុខភាពសាធារណៈ បង្អាក់ការ ប្រមូលផ្ដុំ ប៉ះពាល់លើវិស័យសេវាកម្ម និងទេសចរណ៍ ជាដើម ដែលបានធ្វើឱ្យមនុស្សរាប់សិបលាននាក់បាត់បង់ការងារ និងធ្លាក់ក្នុងភាពក្រីក្រ ។ ដោយឡែកប្រទេសកម្ពុជាយើងវិញ ក៏មិនអាចគេចផុតពីមេរោគនេះបានឡើយ តែដោយមានការដឹកនាំដ៏ត្រឹមត្រូវ និងប្រកបដោយភាព ឈ្លាសវៃរបស់ថ្នាក់ដឹកនាំ រាជរដ្ឋាភិបាល ធ្វើឱ្យយើងអាចគ្រប់គ្រងជំងឺនេះបានយ៉ាងល្អ និងទាន់ពេលវេលា។ សម្ដេចចក្រីបានសម្ដែងនូវការកោតសរសើរ និងអរគុណជាខ្លាំង ចំពោះក្រុមគ្រូពេទ្យ អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងប្រជាពលរដ្ឋនៅទូទាំងប្រទេសដែលបានចូលរួមអនុវត្តយ៉ាងហ្មត់ចត់នូវវិធានការនានាដែលរាជរដ្ឋាភិបាលបានដាក់ចេញ ជាពិសេសវិធានការសុខាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដល់សហគមន៍ប្រកបដោយជោគ-ជ័យ និងគួរជា ទីមោទនៈ។ ទន្ទឹមនឹងភាពជោគជ័យនេះ យើងក៏មិនត្រូវមានការធ្វេសប្រហែសឡើយ ។ អាជ្ញាធរដែនដែនដីគ្រប់លំដាប់ថ្នាក់បាននឹងកំពុងអនុវត្តនូវវិធានការយ៉ាងម៉ត់ចត់ ជាពិសេសខេត្តដែលនៅជាប់នឹងព្រំដែន ធ្វើយ៉ាងណាគ្រប់គ្រងពលករចំណាកស្រុក ដោយធ្វើចត្តាឡី-ស័កចំនួន ១៤ថ្ងៃ តាមមណ្ឌលខេត្តរបស់ខ្លួន។

សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន បានក្រើនរំឭកចំពោះអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងខេត្តត្បូងឃ្មុំ ត្រូវបន្តរួមគ្នាធ្វើអន្តរាគមន៍ឱ្យទាន់ពេលវេលាដោះស្រាយ បញ្ហាចំពោះមុខ ដូចជា គ្រោះ-ធម្មជាតិ បញ្ហាកង្វះទឹក ជូនបងប្អូនប្រជាពលរដ្ឋ តាមរយៈការថែរក្សាប្រភពទឹក និងការប្រើប្រាស់ទឹកសន្សំសំចៃ ជាមួយនឹងការរក្សាទឹក ក្នុងស្រះ ដោយអាជ្ញាធរគ្រប់មូលដ្ឋាន ត្រូវបង្កើនការយកចិត្តទុកដាក់ និងចាត់វិធានការការពារត្រៀមជាមុន ដោយត្រូវរួមគ្នាធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា៕

សម្តេចក្រឡាហោម ស ខេង ណែនាំកិច្ចការសំខាន់ ជាអាទិភាពឆ្ពោះទៅកាន់ការបោះឆ្នោត

***សម្តេចក្រឡាហោម ស ខេង** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបសកម្មភាពការងារគណៈកម្មាធិការគណបក្សខេត្តព្រៃវែង*

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ **សម្តេចក្រឡាហោម ស ខេង** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារចុះមូលដ្ឋានខេត្តព្រៃវែង និងខេត្តបាត់ដំបង អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបសកម្មភាពការងារគណៈកម្មាធិការគណបក្សខេត្តព្រៃវែង ឆ្នាំ២០២០ និងទិសដៅភារកិច្ចឆ្នាំ២០២១ និងផ្សព្វផ្សាយរបាយការណ៍ ស្តីពីសភាពការណ៍ទូទៅ និងការងារគណបក្សឆ្នាំ២០២០ និងទិសដៅភារកិច្ចឆ្នាំ២០២១ របស់គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជានៅទីស្នាក់ការគណបក្សខេត្តព្រៃវែង ។

សម្តេចក្រឡាហោម ស ខេង បានវាយតម្លៃខ្ពស់ចំពោះឆន្ទៈ និងការប្តេជ្ញាចិត្តរបស់ឯកឧត្តម លោកជំទាវ លោកស្រីអស់លោកទាំងអស់ដែលបានស្ម័គ្រចិត្តចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា ក្នុងការធ្វើសកម្មភាពនានាបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាជន ដែលធ្វើឱ្យមានអត្ថិភាពនៃគណបក្សប្រជាជនកម្ពុជា ប្រមាណជិត៧០ឆ្នាំ កន្លងមក ព្រមទាំងបន្តអត្ថិភាពទៅថ្ងៃអនាគតទៀតជាមួយនឹងសមិទ្ធផលជាប្រវត្តិសាស្ត្រយ៉ាងច្រើនឥតគណនា ។ តាងនាមសម្តេចតេជោប្រធានគណបក្ស ក្នុងនាមថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា ដើម្បីបន្តពង្រឹងការជឿជាក់ និងការគាំទ្ររបស់ប្រជាពលរដ្ឋមកលើគណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាឆ្នាំ២០២២ ខាងមុខ **សម្តេចក្រឡាហោម ស ខេង** អនុប្រធានគណបក្សបានធ្វើការណែនាំអំពីកិច្ចការសំខាន់ៗមួយចំនួន និងបានលើកឡើងនូវកិច្ចការជាអាទិភាពមួយចំនួនផងដែរ សម្រាប់ក្រុមការងារ និងគណៈបក្សគ្រប់ថ្នាក់នៃខេត្តព្រៃវែង ធ្វើជាមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពអនុវត្តជាក់ស្តែងក្នុងឆ្នាំ២០២១ដែលរួមមាន៖ **១**-ការពង្រឹងអង្គការចាត់តាំងបក្ស ក្រុមការងារគណបក្ស និងការពង្រឹងពង្រីកសមាជិកបក្ស **២**-ជំរុញអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពី ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព **៣**- បន្តពង្រឹងអភិបាលកិច្ចល្អនៅតាមស្ថាប័នសាធារណៈគ្រប់ថ្នាក់ ដើម្បីលើកកម្ពស់ការបម្រើប្រជាពលរដ្ឋ និង**៤**-ការពង្រឹងរដ្ឋបាលឃុំ សង្កាត់ ភូមិ ។

សម្តេចក្រឡាហោមបានថ្លែងថា កម្ពុជាយើងធ្លាប់ជាប្រទេស ដែលទទួលរងគ្រោះដោយសារសង្គ្រាមត្រជាក់រវាងមហាអំណាច រហូតធ្វើឱ្យប្រទេសជាតិធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ របបប្រល័យពូជសាសន៍ដែលបានបំផ្លិចបំផ្លាញសង្គមជាតិស្ទើររលាយទាំងស្រុង ទម្រាំទទួលបានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ដូចបច្ចុប្បន្ន។ ផ្អែកលើមេរៀនបទពិសោធន៍នេះរាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានធ្វើការដឹកនាំ គ្រប់គ្រងប្រទេសប្រកបដោយភាពបត់បែនប្រកាន់ជំហរអព្យាក្រឹត និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃទៀត ហើយក៏មិនអនុញ្ញាតឱ្យប្រទេសណាមួយជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា ឬយកកម្ពុជាធ្វើជាឈ្នាន់ដើម្បីបំផ្លាញប្រទេសណាមួយឡើយ។

ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ សម្តេចក្រឡាហោមថ្លែងថា ជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសេដ្ឋកិច្ច សង្គមកម្ពុជា និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ស្ថិតក្នុងកាលៈទេសៈដ៏លំបាកនេះ រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានដាក់ចេញផែនការយុទ្ធសាស្ត្រ ដោយផ្តោតទៅលើមុខព្រួញចំនួន០៤ គឺការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដើម្បីទប់ស្កាត់ការឆ្លង និងការការពារអាយុជីវិតប្រជាពលរដ្ឋ ការរក្សាលំនឹងជីវភាពប្រជាពលរដ្ឋ ការខិតខំជួយជំរុញគាំទ្រឱ្យធុរកិច្ច និងអាជីវកម្មអាចរស់បាននិងរក្សាការងារ និងការរក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម។

ទាក់ទិនទៅនឹងគណបក្សនយោបាយ សម្តេចក្រឡាហោមបានគូសបញ្ជាក់ថា គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ បាននិងកំពុងធ្វើសកម្មភាពយ៉ាងសកម្ម ដូចជាការចុះជួបប្រជាពលរដ្ឋ និងអ្នកគាំទ្រ ការពង្រីកសមាជិកថ្មីនៅតាមមូលដ្ឋាន ការថ្លែងសារនយោបាយជាសាធារណៈ ការបើកទីស្នាក់ការ និងការលើកស្លាកគណបក្សដែលទាំងនេះគឺជាដំណើរការនៃរបបពហុបក្សនិយម។ ជាមួយនេះ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយនានា បាននិងកំពុងធ្វើសកម្មភាពយ៉ាងសកម្ម ចូលរួមក្នុងដំណើរការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ ការលើកស្ទួយសិទ្ធិសេរីភាព និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍ៕

សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ៖ កត្តាដែលនាំឲ្យយើងទទួលបានជ័យជម្នះ គឺសាមគ្គីភាព និងឯកភាពផ្ទៃក្នុង

សម្ដេចភក្ដី សាយ ឈុំ អញ្ជើញចុះសាកសួរសុខទុក្ខមន្ត្រី និង អាជ្ញាធរសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

នាព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** អនុប្រធានគណបក្ស ប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះសាកសួរសុខទុក្ខមន្ត្រី និង អាជ្ញាធរសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ លោកស្រីចៅសង្កាត់បានរាយការណ៍អំពីសភាពការណ៍ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការអនុវត្តគោលនយោបាយ ភូមិ សង្កាត់ មានសុវត្ថិភាព ការងារបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ការលំបាក បញ្ហាប្រឈមខ្លះៗដែលអាជ្ញាធរសង្កាត់ និងមន្ត្រីមូលដ្ឋានបានជួប និង បានសម្រួលដោះស្រាយកន្លងមក។

សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ បានសម្ដែងនូវក្ដីសប្បាយរីករាយ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរសង្កាត់ និងមន្ត្រីមូលដ្ឋានទាំងអស់។ សម្ដេចភក្ដីបានលើកឡើង អំពីសភាពការណ៍ និងវឌ្ឍនភាពការងារនៃវិស័យជាច្រើនរបស់រាជរដ្ឋាភិបាល ព្រមទាំងសមិទ្ធផលធំៗថ្មីៗ របស់សង្គមជាតិយើងដែលសម្រេចបាន នាពេលកន្លងមកនេះ។ សម្ដេចវិបុលសេនាភក្ដី បានលើកទឹកចិត្តដល់អភិបាលខណ្ឌ និងមន្ត្រីពាក់ព័ន្ធសូមឱ្យយកចិត្តទុកដាក់សម្រួលដោះស្រាយបញ្ហាលំបាក និងសំណូមពររបស់ប្រជាជននៅមូលដ្ឋានឱ្យបានសមស្របឆាប់រហ័សស្របតាមនិតិវិធីច្បាប់។

សម្ដេចវិបុលសេនាភក្ដី ធ្វើការណែនាំ និងចង្អុលបង្ហាញដល់មន្ត្រីសង្កាត់ និងមន្ត្រីមូលដ្ឋាននូវចំណុចសំខាន់ៗមួយចំនួនជាអាទិ៍ **១**-បន្តខិតខំអនុវត្តឱ្យកាន់តែល្អតាមតួនាទីភារកិច្ច ជាពិសេសយកចិត្តទុកដាក់ចំពោះការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ដោយផ្ដោតលើការរក្សា សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន ចាត់វិធានការបង្ក្រាប ទប់ស្កាត់បទល្មើសនានារួមទាំងបញ្ហា គ្រឿងញៀន **២**-ផ្ដល់សេវាសាធារណៈ បម្រើប្រជាជនដោយគ្មានការរើសអើង និង ប្រកបដោយតម្លាភាព គុណភាព ប្រសិទ្ធភាព និងឆាប់រហ័ស **៣**-បង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការរក្សាការពារធនធាន ទ្រព្យសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដែលមាននៅក្នុងមូលដ្ឋានសង្កាត់របស់យើងឲ្យបានល្អ **៤**-យកចិត្តទុកដាក់តាមដាន និងដោះស្រាយជូនប្រជាជនដែលជួបការលំបាក និងអ្នកដែលរងគ្រោះដោយបង្កុលក្ខណៈ និងលើកទឹកចិត្តជំរុញអាជីវកម្ម ផលិតកម្មជាលក្ខណៈគ្រួសារ ដើម្បីទ្រទ្រង់ និងលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូននៅក្នុងដំណាក់កាលនៃជំងឺកូវីដ- ១៩ **៥**-មន្ត្រី កងកម្លាំងមានសមត្ថកិច្ចត្រូវបន្តយកចិត្តទុកដាក់ អប់រំ និង ផ្សព្វផ្សាយដល់ប្រជាជនយើង ឲ្យខិតខំអនុវត្តរាល់វិធានការរបស់រាជ-រដ្ឋាភិបាល និងក្រសួងសុខាភិបាល **៦**-ក្មួយៗយុវជនដែលជាកម្លាំងបន្តវេនរបស់សង្គមជាតិ ត្រូវខិតខំប្រឹងប្រែងធ្វើការងារផង រៀនសូត្រផង ដកពិសោធន៍ផង ដើម្បីបង្កើនសមត្ថភាព លទ្ធភាព ជួយខ្លួនឯង ផ្ទាល់ផង ជួយក្រុមគ្រួសារ និងរួមចំណែកជួយសង្គមជាតិ និងប្រទេសជាតិផង និង**៧**-ចំពោះការងារបំពេញភារកិច្ច ក៏ដូចជាក្នុងជីវភាពរស់នៅប្រកបមុខរបរអាជីវកម្មនានា គឺមានកត្តារួមផ្សំជាច្រើនដែលនាំយើងឱ្យទទួលជោគជ័យ ក៏ប៉ុន្តែកត្តាដែលសំខាន់មិនអាចខ្វះបាននោះគឺ សាមគ្គីភាព និងឯកភាពផ្ទៃក្នុងរបស់យើង គឺត្រូវតែរឹងមាំ ហើយមិនត្រូវធ្វេសប្រហែសភ្លេចខ្លួនឡើយ។

សម្ដេចភក្ដី សាយ ឈុំ ក៏បានអញ្ជើញចុះពិនិត្យភូមិសាស្ត្រនៃសង្កាត់ ព្រមទាំងបានពិនិត្យទីតាំងដីសម្រាប់ការសាងសង់អគារសាលាសង្កាត់ថ្មី ដែលមានទំហំក្បាលដីប្រវែង២០ម៉ែត្រ និងជម្រៅប្រវែង ១៦ម៉ែត្រ ស្ថិតនៅភូមិកាកាបផងដែរ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ខន ៖ ការកសាងសហគមន៍ជោគវាសនារួមកម្ពុជា-ចិនកាន់តែមានសន្ទុះខ្លាំងក្លា

*ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** ដឹកនាំប្រតិភូគណបក្សចូលរួមកិច្ចប្រជុំសង្ខេបខ្លឹមសារស្ដីពី □ដំណើររឿងរបស់គណបក្សកុម្មុយនីស្ដចិនក្រោមប្រធានបទ ៖ ធ្វើឲ្យជីវិតទាំងអស់គ្នាប្រសើរឡើង□*

តបតាមការអញ្ជើញរបស់ក្រសួងទំនាក់ទំនងអន្តរជាតិនៃគណៈ-កម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ដចិន និងទទួលបានការចាត់តាំងពីគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** សមាជិក គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលតំណាងឱ្យគណបក្សប្រជាជនកម្ពុជា បានដឹកនាំប្រតិភូគណបក្ស ចូលរួមកិច្ចប្រជុំសង្ខេបខ្លឹមសារស្ដីពី□**ដំណើររឿងរបស់គណបក្សកុម្មុយនីស្ដចិនក្រោមប្រធានបទ ៖ ធ្វើឲ្យជីវិតទាំងអស់គ្នាប្រសើរឡើង□**ដែលសហការរៀបចំដោយក្រសួងទំនាក់ទំនងអន្តរជាតិនៃ គណៈកម្មាធិការមជ្ឈិមបក្ស-កុម្មុយនីស្ដចិន និងគណៈកម្មាធិការបក្សកុម្មុយនីស្ដចិនប្រចាំតំបន់ស្វយ័តស៊ីនជាំង-អ៊ុយហ្គួរ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអ៊ីនធឺណែត ពីប្រតិភូ ចំនួនជាង ៣០០រូប និង៨០ប្រទេស ព្រមទាំងមានការចូលរួមពីគណបក្សនយោបាយ អង្គការសង្គមស៊ីវិល អ្នកសារព័ត៌មាន និងក្រុមអ្នកប្រាជ្ញ (Think Tank) ក្នុងតំបន់និងពិភពលោកប្រមាណជាង២០០ ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** បានថ្លែងសន្ទរកថាគន្លឹះ ដោយបានគូសបញ្ជាក់ថា ជំងឺកូវីដ-១៩ បាននិងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច សុខមាលភាព និងអាយុជីវិតមនុស្សរាប់លាននាក់ជុំវិញពិភពលោក។ ក្នុងន័យនេះ ឯកឧត្តមបានលើកទឹកចិត្តដល់ប្រទេសទាំងអស់ បន្តចាត់ទុកអាយុជីវិត សុវត្ថិភាព និងសុខភាពរបស់ប្រជាជន ជាអាទិភាពខ្ពស់ ព្រមទាំងជំរុញសាមគ្គីភាពជាសកលដើម្បីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងចក្ខុវិស័យនៃការកសាងសហគមន៍សុខភាពពិភពលោកសម្រាប់មនុស្សទាំងអស់ និងស្មើៗគ្នា។ ប្រទេសទាំងអស់ត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងចាត់វិធានការសមស្របនានា ដើម្បីរួមគ្នាស្ដារសេដ្ឋកិច្ចពិភពលោកឡើងវិញក្រោយវិបត្តិកូវីដ-១៩ តាមរយៈ ការសម្របសម្រួលគោល-នយោបាយម៉ាក្រូសេដ្ឋកិច្ច ការថែរក្សាឱ្យបាននូវស្ថិរភាពទីផ្សារហិរញ្ញវត្ថុ ការធានាខ្សែចង្វាក់ផ្គត់ផ្គង់ និងខ្សែចង្វាក់ឧស្សាហកម្ម ការកាត់បន្ថយបំណុល និងការជំរុញលំហូរពាណិជ្ជកម្មពិភពលោក។

ទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស ឯកឧត្តមសូមគាំទ្រចំពោះការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ដែលក្នុងនោះសិទ្ធិរស់រានមានជីវិត និងសិទ្ធិទទួលបានការអភិវឌ្ឍន៍គឺជាមូលដ្ឋានគ្រឹះ។ ភាពក្រីក្រគឺជាឧបសគ្គចម្បងចំពោះការសម្រេចបាននូវសិទ្ធិមនុស្ស។ ផលប្រយោជន៍របស់ប្រជាជនគួរតែត្រូវបានគេចាត់ទុកជាកិច្ចការដ៏សំខាន់បំផុត ហើយការអភិវឌ្ឍគួរតែផ្ដល់នូវអត្ថប្រយោជន៍កាន់តែច្រើនដល់ប្រជាជនទាំងអស់ប្រកបដោយសមធម៌ ។

ឯកឧត្តមបានថ្លែងបញ្ជាក់ថា គ្មានគំរូណាមួយដែលត្រូវគ្រប់ស្ថានភាពទាំងអស់នោះទេ សម្រាប់ការការពារ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស។ភាពចម្រុះនៅក្នុងមាគ៌ានៃការអភិវឌ្ឍសិទ្ធិមនុស្សគួរត្រូវបានគោរព ហើយរាល់ការប៉ុនប៉ងទាំងឡាយណាក្នុងការយកបញ្ហាសិទ្ធិមនុស្សធ្វើជាបញ្ហានយោបាយ ការអនុវត្តស្តង់ដារពីរ ឬយកហេតុផលសិទ្ធិមនុស្ស ដើម្បីជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ប្រទេសដ៏ទៃគួរត្រូវបានបដិសេធ។ ឯកឧត្តមបានលើកទឹកចិត្តឲ្យមានការខិតខំប្រឹងប្រែងរួមគ្នារបស់គ្រប់ភាគីទាំងអស់ ដោយឈរលើគោលការណ៍គោរពសិទ្ធិអធិបតេយ្យ និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ ដើម្បីជំរុញនិម្មាបនកម្មអភិបាលកិច្ចពិភពលោកស្ដីពីសិទ្ធិមនុស្ស ដែលមានសមធម៌ យុត្តិធម៌ បរិយាប័ន្ន និងមានលក្ខណៈទូលំទូលាយជាងមុន។

ឯកឧត្តមបានបន្ថែមថា ការជួបប្រជុំគ្នានៅថ្ងៃនេះ បានជួយឱ្យយើងទទួលបានការយល់ដឹងគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅអំពីគោលនយោបាយរបស់ចិនទាក់ទងនឹងក្រុមជនជាតិភាគតិច និងការអភិវឌ្ឍតំបន់ដែលមានប្រជាជនជាជនជាតិភាគតិចរស់នៅច្រើន រួមទាំងស្ថានភាពជាក់ស្ដែងនៅស៊ីន ជាំង ដែលសេដ្ឋកិច្ច ស្ថិរភាពសង្គម សមភាព និងសាមគ្គីភាពក្នុងចំណោមក្រុមជនជាតិផ្សេងៗគ្នា និងជីវភាពរស់នៅរបស់ប្រជាជននៅតែមានភាពប្រសើរ ឥតឈប់ឈរ។

ឆ្លៀតឱកាសនេះឯកឧត្តមបានថ្លែងអំណរគុណចំពោះបក្សរដ្ឋាភិបាល និងប្រជាជនចិន ដែលបានជួយឧបត្ថម្ភគាំទ្រកម្ពុជា ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដែលបានចូលរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ តាមរយៈការបញ្ជូនគ្រូពេទ្យជំនាញ គ្រឿងបរិក្ខារវេជ្ជសាស្ត្រ និងការផ្ដល់ជំនួយវ៉ាក់សាំងជូនកម្ពុជា ។ គណបក្សប្រជាជនកម្ពុជា មានឆន្ទៈក្នុងការពង្រឹងការផ្លាស់ប្ដូរនិងការរៀនសូត្រទៅវិញទៅមកជាមួយគណ-បក្ស កុម្មុយនីស្ដចិន លើបទពិសោធន៍អភិបាលកិច្ច ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅដែលផ្ដល់ផលប្រយោជន៍ទៅវិញទៅមក ដើម្បីជំរុញការកសាងសហគមន៍ជោគវាសនារួម ចិន-កម្ពុជា ឱ្យកាន់តែមានសន្ទុះខ្លាំងក្លាឡើងថែមទៀត សំដៅចូលរួមចំណែកដល់ការកសាងសហគមន៍ជោគវាសនារួមសម្រាប់មនុស្សជាតិ ។

នៅចុងបញ្ចប់ អង្គប្រជុំបានប្រកាសអនុម័តសេចក្ដីថ្លែងការណ៍រួមស្ដីពី **□ដំណើររឿងរបស់គណបក្សកុម្មុយនីស្ដចិន ៖ សេចក្ដីសង្ខេបអំពីបញ្ហានៅស៊ីនជាំង □ ៕**

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ប្រាសាទបុរាណកណ្តាលស្រះស្រង់ និងរហាត់ ទឹកបុរាណ នៅក្នុងរមណីយដ្ឋានអង្គរ។ លោកជំទាវកិត្តិសង្គហបណ្ឌិតក៏បាននាំយកអំណោយនិងថវិការបស់សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ចែកជូនប្រជាពលរដ្ឋចំនួន ៧០០គ្រួសារ រួមទាំងក្រុមជាងនិងកងកម្លាំងទាំងបីប្រភេទផងដែរ ។

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១ ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយអង្គបោះឆ្នោតព្រឹទ្ធសភាខណ្ឌព្រែកព្នៅ ដោយមាន សមាជិកក្រុមប្រឹក្សាសង្កាត់ចូលរួមចំនួន៣៤រូប រួមជាមួយនឹងប្រធានក្រុមប្រឹក្សាខណ្ឌ លោកអភិបាល អភិបាលរង និងថ្នាក់ដឹកនាំខណ្ឌ នៅសាលាខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តម **កៃ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ បានអញ្ជើញចុះសួរសុខទុក្ខក្រុមគ្រូពេទ្យនិងមន្ត្រីប្រចាំការជួរមុខនៅមជ្ឈមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចឪ ស្ថិតនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ឯកឧត្តម បានឧបត្ថម្ភដល់មជ្ឈមណ្ឌលចត្តាឡីស័កទាំង១៣ របស់ខេត្តបន្ទាយមានជ័យ មាន ម៉ាស់ចំនួន១០ម៉ឺនបន្ទះ និងថវិកាឧបត្ថម្ភសរុបចំនួន ២៦លានរៀល ។

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង បានអញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលស្រុកកំពង់ត្រឡាច នៅសាលាស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បាននាំយកសម្ភារៈមួយចំនួនជូនដល់រដ្ឋបាលស្រុកកំពង់ត្រឡាច រួមមាន៖ អង្ករផ្កាខ្ញី ចំនួន ២តោន មី ១០កេស ទឹកត្រី ១០ យួរ ទឹកស៊ីអ៊ីវ ១០យួរ ប្រេងឆា ៦០ដប ម៉ាស់ ១ម៉ឺន ម៉ាស់ សាប៊ូដុំ ៧២០ ដុំ សាប៊ូ លាងចាន ៣០ លីត្រ អាល់កុលលាងដៃ ៦០ លីត្រ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ឯកឧត្តម **មាស សុភា** សមាជិកគណៈចិន្ត្រ្រ័យនៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះមូលដ្ឋានខេត្តព្រះវិហារ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធអគារស្នាក់ការថ្មីរបស់គណបក្សប្រជាជនកម្ពុជា ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ និងសមិទ្ធផលជាច្រើនទៀត មានតម្លៃជាង១០០លានរៀល។ឯកឧត្តមថ្លែងថា នេះជាសមិទ្ធផលរួមរបស់គណបក្សប្រជាជនកម្ពុជា ដែលបានមកពីការចូលរួមចំណែករបស់ក្រុមការងារថ្នាក់កណ្តាល ថ្នាក់ ខេត្ត ចុះជួយស្រុក សង្គមថ្មី ។

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានា ក្នុងវត្តជោតិរង្សី ហៅវត្តបុស្ស ស្ថិតនៅឃុំរូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធការិយាល័យទីស្នាក់ការគយ និងរដ្ឋាករត្រពាំងផ្លុងស្ថិតក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យថ្លែងថា ការសម្ពោធដាក់ឱ្យប្រើប្រាស់ការិយាល័យថ្មីនេះ គឺជារៀបចំឱ្យមានកន្លែងសម្រាប់ធ្វើការសមរម្យ សម្រាប់ថ្នាក់ដឹកនាំមន្ត្រីរាជការ ក្នុងការបំពេញការងារគយ និង រដ្ឋាករកាន់តែល្អប្រសើរឡើង ដូច្នេះមន្ត្រីគយទាំងអស់ដែលបំពេញការងារនៅតាមច្រកទ្វារនេះ ត្រូវខិតខំបំពេញការងារតាមតារាងលំហូរនៃនីតិវិធីដោយប្រកាន់យកអភិក្រមបួនយ៉ាងគឺការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈអនុវត្តការងារជាក្រុម ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងមិនត្រូវមើលរំលងកំហុសខ្លួនឯង។

ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន អនុញ្ញាតឱ្យ ឯកឧត្តម ប៉ាទ្រីក មឺហ្វី (W. Patrick Murphy) ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួងព័ត៌មាន។

ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម អនុប្រធានក្រុមការងារគណៈពង្រឹងមូលដ្ឋានខេត្តកណ្តាល និងជាប្រធានគណៈពង្រឹងមូលដ្ឋានស្រុកពញាឮ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធអគារស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកពញាឮ ខេត្តកណ្តាល។ ពិធីនេះមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តមថ្នាក់ដឹកនាំខេត្ត និងអស់លោកលោកស្រីជាក្រុមការងារសរុបជាង២៥០នាក់។

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិត **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម **ខួន រតនៈ** អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង អញ្ជើញចុះពិនិត្យស្ថានភាពមណ្ឌលចត្តាឡីស័ក ស្រុកកំរៀង ខេត្តបាត់ដំបង ។ ឯកឧត្តមបណ្ឌិត បានអំពាវនាវដល់ពលករខ្មែរ ដែលកំពុងធ្វើការនៅ ប្រទេសថៃ សូមកុំសម្រុកមកលេងស្រុកកំណើត ក្នុងរដូវបុណ្យចូលឆ្នាំប្រពៃណីជាតិខាងមុខ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ជាមួយរាជរដ្ឋាភិបាល។

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ឯកឧត្តម **ព្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាល គណបក្ស ប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួង មុខងារសាធារណៈ និងជាប្រធានក្រុមការងារចុះមូលដ្ឋានខេត្តក្រចេះ បានអញ្ជើញចុះជួយគាំទ្រដល់ការងាររៀបចំធ្វើបច្ចុប្បន្នភាពសមាជិកគណបក្សប្រជាជនកម្ពុជារបស់ មន្ត្រីមូលដ្ឋានក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ។ ឯកឧត្តមបានលើកឡើងនូវចំណុចសំខាន់ទាំង៣ ស្របតាមស្មារតីសេចក្តីណែនាំរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ក្នុងការប្រមូលកម្លាំងសរុប សហការជំរុញការធ្វើបច្ចុប្បន្នភាពសមាជិកគណបក្សឱ្យបានម៉ត់ចត់ ត្រឹមត្រូវ ដើម្បីធ្វើឱ្យការគ្រប់គ្រងទិន្នន័យធានាបានដោយពិតប្រាកដថា សមាជិកគណបក្សមួយរូប គឺជាសម្លេងឆ្នោតគាំទ្រគណបក្សយើងមួយសន្លឹក។ ដោយឡែកនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ឯកឧត្តម **ព្រុំ សុខា** បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ស្តីពីសភាពការណ៍ទូទៅ និងការងារគណបក្សឆ្នាំ២០២០ និងទិសដៅភារកិច្ចឆ្នាំ២០២១ ដោយមានការចូលរួមពីសំណាក់អស់លោក លោកស្រីជាមន្ត្រីដឹកនាំតាមក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងគណៈអចិន្ត្រៃយ៍បក្សស្រុក ប្រធានសាខាបក្សការិយាល័យជុំវិញស្រុក ប្រធានបក្សឃុំ ប្រធានសាខាបក្សភូមិទាំង ១០៨ សរុបមានអ្នកចូលរួមទាំងអស់ចំនួន ២៨៩នាក់ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាស្រុកបាភ្នំ។ បន្ទាប់ពីបានរៀនសូត្រតាមការវាយតម្លៃសន្និដ្ឋានរបស់គណៈអចិន្ត្រៃយ៍គណបក្សប្រជាជនកម្ពុជា អង្គប្រជុំទាំងមូលបានប្តេជ្ញារួមសាមគ្គីជាធ្លុងមួយដើម្បីជំរុញអនុវត្តឱ្យបានសម្រេចដោយជោគជ័យនូវរាល់ទិសដៅភារកិច្ចឆ្នាំ២០២១សំដៅបន្តពង្រឹងប្រៀបនិងកម្លាំងនយោបាយរឹងមាំរបស់ស្រុកបាភ្នំទាំងមូល សម្រាប់ការបោះឆ្នោតឆ្នាំ២០២២ និងឆ្នាំ២០២៣ ។

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ម៉ម ប៊ុននាង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការ ទី១០ បានអញ្ជើញចូលរួមសវនាការប្រចាំឆ្នាំរបស់សហភាពអន្តរសភា (IPU) និងអង្គការសហប្រជាជាតិ (UN) ដឹកនាំដោយឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការទី៥ រដ្ឋសភា តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីទីក្រុងញ៉ូវយ៉ក ក្រោមប្រធានបទស្តីពីការ □**ប្រយុទ្ធនឹងអំពើពុករលួយ ដើម្បីស្តារឡើងវិញនូវទំនុកចិត្តលើរដ្ឋាភិបាល និងធ្វើឱ្យប្រសើរឡើងវិញនូវទស្សនវិស័យនៃការអភិវឌ្ឍ**□ នៅវិមានរដ្ឋសភា។

ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ជាម ប៉េអា** អ្នកតំណាងរាស្ត្រខេត្តព្រៃវែង បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្ពានឈើប្រវែង៣០ម៉ែត្រ និងផ្លូវបេតុងប្រវែង១២០ម៉ែត្រ ដើម្បីសម្រួលដល់ការធ្វើដំណើរជូនប្រជាពលរដ្ឋ និងការដឹកជញ្ជូនកសិផល ដែលជាមូលនិធិឃុំព្រែកចង្ក្រាន និងការចូលរួមពីសប្បុរសជន ស្ថិតនៅវត្តព្រែកចង្ក្រានក្រោម ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្តាលខេត្តព្រៃវែង។ កម្មវិធីនេះមានប្រជាពលរដ្ឋចូលរួមប្រមាណ ១៥០នាក់ ដោយប្រកាន់ខ្ជាប់នូវវិធានសុខាភិបាលក្នុងការការពារជំងឺឆ្លងកូវីដ-១៩។ ឯកឧត្តមអ្នកតំណាងរាស្ត្របានអំពាវនាវប្រជាពលចូលរួមថែរក្សា និងប្រើប្រាស់សមិទ្ធផលដែលសម្រេចបានថ្មីឲ្យបានយូរអង្វែង។

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ស្បោង សារ៉ាត** សមាជិកគណៈកម្មាធិកាកណ្តាលនិងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តព្រៃវែង បានអញ្ជើញជាអធិបតីក្នុងពិធីកាត់ខ្សែបូបុណ្យឆ្លងឧបដ្ឋានសាលាសមិទ្ធផលនានាពុទ្ធាភិសេក និងស្រោចស្រពសុគន្ធវារីប្រគេនព្រះគ្រូចៅអធិការវត្តចុងក្រូច ឃុំរាប ស្រុកពារាំង ខេត្តព្រៃវែង ។ ឯកឧត្តម និងសហការី បាននាំយកបច្ច័យចូលបុណ្យសរុបចំនួន៣០.២៧០.០០០រៀល និងឧបត្ថម្ភលោកគ្រូអ្នកគ្រូ១០នាក់ ក្នុងម្នាក់ៗទទួលបានថវិកា ២០.០០០ រៀល លោកគ្រូពេទ្យចំនួន ៥នាក់ម្នាក់ៗ ២០.០០០ រៀល ឧបត្ថម្ភ យុវជនកាយឬទ្ធិ១០នាក់ យុវជន ស.ស.យ.ក ១០នាក់ យុវជនកាកបាទក្រហម ១០នាក់ សរុប៣០នាក់ ក្នុងម្នាក់ៗ ទទួលបាន១០,០០០រៀល ជូនយាយជី តាជី ២៥នាក់ ក្នុងម្នាក់ៗទទួលបាន ក្រណាត់ស១ដុំ ថវិកា២០.០០០រៀលផងដែរ ។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ទី សំណាង** សមាជិកគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌របស់សាខាកាកបាទក្រហមកម្ពុជាខេត្ត ចែកជូនប្រជាពលរដ្ឋ ក្រីក្រ ខ្វះខាត គ្មានទីពឹង និងងាយរងគ្រោះ ចំនួន ៧៤គ្រួសារ ស្ថិតនៅភូមិត្រពាំងដងទឹក ឃុំទ័ពមាន ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងបានប្រគល់ផ្ទះ ០៤ខ្នង ជូនដល់ប្រជាពលរដ្ឋ ០៤គ្រួសារ ។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ លោកជំទាវ **មិថុនា ភូថង** សមាជិកា-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈ-អភិបាលខេត្តកោះកុង និងជាប្រធានសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានអញ្ជើញជួបសំណេះសំណាលជាមួយគ្រួសារពលករ ដែលត្រូវបញ្ជូនចេញទៅកាន់លំនៅឋានវិញ បន្ទាប់ពីបានធ្វើចត្តាឡីស័កគ្រប់១៤ថ្ងៃ។

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **វ៉ា ថន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តក្រចេះ បានអញ្ជើញជាអធិបតីក្នុងវេទិកាពិគ្រោះយោបល់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូរវាងរដ្ឋបាលខេត្ត និងអង្គការសង្គមស៊ីវិល ដែលកំពុងប្រតិបត្តិការនៅក្នុងខេត្តក្រចេះ ។ ឯកឧត្តមបានលើកទឹកចិត្តឱ្យអង្គការសង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពនៅលើទឹកដីខេត្តក្រចេះ បន្តកិច្ចសហការឱ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយរាជរដ្ឋាភិបាល ជាពិសេសជាមួយអាជ្ញាធរមូលដ្ឋានដើម្បីពង្រឹងសាមគ្គីភាពផ្ទៃក្នុង។

ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ ២០២១ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលខេត្តកំពត បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពានដំរីផុងស្ថិតនៅក្នុងភូមិកំពង់ចិន ឃុំស្នឹងកែវ ស្រុកទឹកឈូ ខេត្តកំពតដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្តេច-កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ដោយមានការអញ្ជើញ ចូលរួមពីឯកឧត្តមអភិបាលរងខេត្ត ប្រធានមន្ទីរអង្គភាពជំនាញជុំវិញខេត្ត កងកម្លាំង លោកអភិបាលក្រុង ស្រុក អាជ្ញាធរមូលដ្ឋានភូមិឃុំ ព្រះសង្ឃ បងប្អូនប្រជាពលរដ្ឋ សរុបប្រមាណជា ៥០០ នាក់។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានដឹកនាំកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ដើម្បីពិនិត្យ និងពិភាក្សាសម្រេចលើសេចក្ដីព្រាងលិខិតបទដ្ឋាននានា របស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ដែលមានការចូលរួមពីសមាជិក សមាជិកា គណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ក្រុមការងារសរុបចំនួន ៤០នាក់ នៅទីស្នាក់ការកណ្ដាលគណបក្សប្រជាជនកម្ពុជា (វិមាន ៧មករា)។

ប្រធានបណ្ដាផ្នែកចំណុះនៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងជាប្រធានយុវជន គណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសរចនាសម្ព័ន្ធ នឹងប្រកាសទទួលស្គាល់សមាសភាព ក្រុមជំនួយការតាមផ្នែកនីមួយៗនៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលរួមមាន៖ ផ្នែកចាត់តាំងចំនួន ៥០រូប, ផ្នែកឃោសនាអប់រំ ចំនួន ៥៥រូប, ផ្នែកព័ត៌មាន និងបណ្ដាញផ្សព្វផ្សាយសង្គម ចំនួន ៩៤រូប, ផ្នែករាជធានី ខេត្ត ចំនួន ១៦២រូប, ផ្នែកក្រៅប្រទេស ចំនួន ២៣១រូប, ផ្នែកគ្រឹះស្ថានសិក្សា ចំនួន ៨៧រូប នឹងផ្នែកសិល្បៈ និងកីឡា ចំនួន ៦៥រូប នៅទីស្នាក់ការកណ្ដាល គណបក្សប្រជាជនកម្ពុជា (វិមាន ៧មករា) និងនៅមន្ទីរគណបក្សរាជធានីភ្នំពេញ(ផ្លូវ ២០០៤)។

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ជួន ថេវ៉ាច័ត** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍នៃយុវជន គណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានផ្នែកក្រសួង-ស្ថាប័ន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានដឹកនាំកិច្ច ប្រជុំពិភាក្សារវាងផ្នែកក្រសួង ស្ថាប័ន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងក្រុមការងារយុវជនគណបក្សក្រសួង ស្ថាប័ន នឹងមានការអញ្ជើញជាគណៈអធិបតីភាព ឯកឧត្តម រិន វីរៈ សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានផ្នែកចាត់តាំង នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ក្នុងពិធីដើម្បីផ្សព្វផ្សាយនូវលិខិតបទដ្ឋាននានា របស់យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ជូនឯកឧត្តមថ្នាក់ដឹកនាំ និងសមាជិក សមាជិកា ផ្នែកក្រសួង ស្ថាប័ន និងប្រធានក្រុមការងារយុវជនគណបក្សក្រសួង ស្ថាប័ន ទាំង៤១ សរុបអ្នកចូលរួមចំនួន ៨០នាក់ នៅទីស្នាក់ការកណ្ដាលគណបក្សប្រជាជនកម្ពុជា (វិមាន ៧មករា)។

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម **ចាយ បូរិន** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលនិងជាប្រធានផ្នែកឃោសនាអប់រំ នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានអញ្ជើញ សួរសុខទុក្ខ ឯកឧត្តម ចាន់ វ៉ែន សមាជិកគណៈកម្មាធិការកណ្ដាល និងជាទីប្រឹក្សាជាន់ខ្ពស់រដ្ឋសភា នៅលំនៅដ្ឋាន បុរីប៉េងហួតបឹងស្នោ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារយុវជនគណបក្សខេត្តព្រះវិហារ បានប្រារព្ធពិធីប្រកាសផ្ទេរមុខតំណែងប្រធានក្រុមការងារយុវជនគណបក្សខេត្តព្រះវិហារ ឯកឧត្តម **យ៉ុខ គឹមហ៊ាន** ត្រូវបានសម្រួលភារកិច្ច បានតែងតាំង លោក **អ៊ុក គឹមសាន្ត** ជាប្រធានក្រុមការងារយុវជនគណបក្សខេត្តព្រះវិហារ ក្រោមអធិបតីភាព ឯកឧត្តម **ប្រាក់ សុវណ្ណ** សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានគណៈកម្មាធិការគណបក្សខេត្ត និងមានការអញ្ជើញចូលរួមពីអនុប្រធានគណៈកម្មាធិការគណបក្ស អនុប្រធានគណៈប្រចាំការ កម្មាធិការគណបក្សខេត្ត និងថ្នាក់ដឹកនាំសមាជិក សមាជិកាក្រុមការងារយុវជនគណបក្សខេត្តព្រះវិហារ នៅស្នាក់ការគណបក្សខេត្តព្រះវិហារ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២១ តាមរយៈឯកឧត្ដម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាលនិងជាអនុប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តកំពង់ចាម ឯកឧត្ដម **ជ្រុន ថេរ៉ាវ៉ាត** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិក គណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានជនបង្គោលយុវជនថ្នាក់កណ្ដាលទទួលបន្ទុកស្រុកព្រៃឈរ ខេត្តកំពង់ចាម បានដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានសាងសង់ ដែលជាសមិទ្ធផលដ៏ថ្លៃថ្លារបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន** បានផ្ដល់ជូននូវអគារសិក្សា ១ខ្នង កម្ពស់២ជាន់ ១០ បន្ទប់ នៅវិទ្យាល័យល្វា និង ផ្លូវបេតុង១ខ្សែ តភ្ជាប់ពីផ្លូវជាតិ៦ ទៅភូមិតុងរ៉ុង ឃុំតុងរ៉ុងប្រវែង ៤គីឡូម៉ែត្រ ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ឯកឧត្ដម **វ៉ា ថន** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តក្រចេះ បានដឹកនាំកិច្ចប្រជុំប្រកាសទទួលស្គាល់ក្រុមជំនួយការផែននានា នៃក្រុមការងារយុវជនគណបក្សខេត្ត ដោយមានការចូលរួមពីគណៈអចិន្ត្រៃយ៍ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្ត សមាជិក សមាជិកា និងក្រុមជំនួយការសរុបចំនួន ៤៥០នាក់ នៅសាលប្រជុំគណបក្សខេត្តក្រចេះ។

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្ដម **ឃួ ឈុនគ្រី** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារគណបក្សចុះជួយឃុំពាំងល្វា បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ទូទៅ ការងារគណបក្សឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ និងជំនួយស្មារតីស្ដីពីការងារអាទិភាពឆ្ពោះទៅកាន់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្ដម **លី សុន** ប្រធានក្រុមការងារគណបក្សចុះជួយស្រុកឧត្ដុង្គ លោក **សុខ សយ** ប្រធានគណបក្សស្រុក និងឯកឧត្ដម លោក អនុប្រធាន សមាជិកក្រុមការងារចុះជួយឃុំពាំងល្វា ស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ នៅស្នាក់ការគណបក្សឃុំពាំងល្វា ។

ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្ដម **ណុប រ័ត្ននិមល** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារ យុវជនគណបក្សខុទ្ទកាល័យ**សម្ដេចតេជោ ហ៊ុន សែន** (ខ៤) បានអញ្ជើញចូលរួមពិធីសំណេះសំណាល និងផ្ដល់នូវអំណោយដ៏ថ្លៃថ្លារបស់**សម្ដេចតេជោ ហ៊ុន សែន** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ជូនដល់យុវជនគណបក្សប្រជាជនកម្ពុជាទាំង១៥ឃុំ និងវិទ្យាល័យទាំង៨ ក្រោមអធិបតីភាព ឯកឧត្ដម **អ៊ូច តា** ប្រធានគណៈកម្មាធិការគណបក្សខេត្ត សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តតាកែវ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្ដមកិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានគណៈកម្មាធិការគណបក្សខុទ្ទកាល័យ**សម្ដេចតេជោ ហ៊ុន សែន** ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្ដម **ហុង ជឿន** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារ យុវជនគណបក្សក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានដឹកនាំកិច្ចប្រជុំពិនិត្យលទ្ធផលការងារអនុវត្តឆ្នាំ២០២០ និងលើកទិសដៅឆ្នាំ២០២១ របស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងពង្រឹង ពង្រីកកសាងសមាជិកជាយុវជនទាំងបរិមាណ និងគុណភាពឆ្ពោះទៅរកប្រៀបឈ្នះក្នុងការបោះឆ្នោត ក្រុមប្រឹក្សាឃុំសង្កាត់នាឆ្នាំ២០២២ និងបោះឆ្នោតសាកលឆ្នាំ២០២៣ និងពិភាក្សាលើការងារកសាងផែនការយុទ្ធសាស្ត្រយុវជនក្នុងដែនសមត្ថកិច្ចរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្រសួង រយៈពេល ៣ឆ្នាំ (២០២១-២០២៣)។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

• ឆ្នាំ២០២០

❋ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី (EAEU)មានចំនួន ៦៧,៣៧លានដុល្លារកើនឡើង ១៨,២២% បើធៀបទៅនឹងឆ្នាំ២០១៩ ដែលមាន ៥៦,៩៨លានដុល្លារ ។ កម្ពុជានាំចេញបាន ៥២,១៩ លានដុល្លារកើនឡើង ០,៧៣% ពី ៥១,៨១ លានដុល្លារ ក្នុងឆ្នាំ២០១៩ និងនាំចូល ១៥,១៨លានដុល្លារ ដែលមានចំនួន១៩៣,៥៧%ពី៥,១៧លានដុល្លារ។ប្រទេសសមាជិកចំនួន ៥ រួមមាន អាមេនី បេឡារុស្ស កាហ្សាក់ស្ថាន កៀហ្ស៊ីស្ថាន និងរុស្ស៊ី មានប្រជាជនសរុប ១៨៤,៦លាននាក់ ចំណែកផលិតផលក្នុងស្រុកសរុប (GDP) មាន ៤,៧៧៨ទ្រីលានដុល្លារ ។

❋ ទំហំពាណិជ្ជកម្ម កម្ពុជា-អាមេរិក មានតម្លៃ ៦៩២១,៣លានដុល្លារ កើន ១៧,៨៩% ។ ទំនិញកម្ពុជានាំចេញទៅទីផ្សារអាមេរិកមានចំនួន ៦៥៧៧,៧លានដុល្លារ កើនឡើង ២២,៧៩% ឯការនាំទំនិញពីអាមេរិកមកកម្ពុជា មានទំហំទឹកប្រាក់ ៣៤៣,៦លានដុល្លារ ធ្លាក់ចុះ ៣៣% ខណៈឆ្នាំ២០១៩ មានទឹកប្រាក់ ៥១៤លានដុល្លារ ។ ទំនិញដែលកម្ពុជានាំចេញទៅទីផ្សារអាមេរិក មានការនាំចេញកង់ កើនឡើង ២០០% ទទួលបានចំណូលជិត ២០០លានដុល្លារ , ការនាំចេញគ្រឿងសង្ហារឹម , ក្តារបន្ទះ , សូឡា និងគ្រឿងអេឡិចត្រូនិក កើនឡើង ២០% ។

❋ ទំហំពាណិជ្ជកម្មទ្វេភាគី កម្ពុជា-ជប៉ុន មានតម្លៃសរុប ២.០៩៩,៥៧ លានដុល្លារ ធ្លាក់ចុះ ៨,៤៥% ក្នុងនោះកម្ពុជានាំចេញទៅទីផ្សារជប៉ុន មានតម្លៃ ១,៦ពាន់លានដុល្លារ ធ្លាក់ចុះ ៦,៧% ឯការនាំទំនិញពីជប៉ុនមកកម្ពុជាមានតម្លៃជាង ៤៨៤លានដុល្លារ ធ្លាក់ចុះ ១៣,៨% ធៀបនឹងឆ្នាំ២០១៩ ។

❋ ទំហំពាណិជ្ជកម្មទ្វេភាគី កម្ពុជា-ថៃ សម្រេចបាន ៧.២៣៦ លានដុល្លារ ធ្លាក់ចុះ ២៣,១៧% ធៀបនឹងឆ្នាំ២០១៩ ដោយសារផលរំខានពីរីករាលដាលជំងឺកូវីដ-១៩ ។ កម្ពុជាបាននាំចេញទំនិញទៅទីផ្សារប្រទេសថៃ ក្នុងតម្លៃ ១.១៤៨លានដុល្លារ ធ្លាក់ចុះ ៤៩,៤៩% ខណៈកម្ពុជានាំចូលពីប្រទេសថៃ មានតម្លៃ ៦.០៨៩ ធ្លាក់ចុះ ១៤,៨០% ។

- ការផ្លាស់ប្តូរពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តារដ្ឋជាសមាជិកនៃប្រទេសអាស៊ានសម្រេចបាន១១,៣៣០ពាន់លានដុល្លារកើនឡើង ២២,៤២% ធៀបនឹង ៩,២៥៤ពាន់លានដុល្លារ កាលពីឆ្នាំ២០១៩ ដែលការផ្លាស់ប្តូរពាណិជ្ជកម្មភាគច្រើន ធ្វើជាមួយប្រទេសជាប់ព្រំដែន ថៃ និងវៀតណាម ។ ការនាំចេញសរុបរបស់កម្ពុជាទៅកាន់បណ្តាប្រទេសសមាជិកអាស៊ាន មានតម្លៃ ៣,៧២៣ពាន់លានដុល្លារ កើនឡើង ១៨៦% ខណៈការនាំចូលមានតម្លៃ ៧,៦០៧ពាន់លានដុល្លារ ធ្លាក់ចុះ ៤,៣៣% ។

• ខែមករា ឆ្នាំ២០២១

❋ កម្ពុជានាំចេញផលិតផលកសិកម្មសំខាន់ៗបានសរុប ២០៣.៤៨៥តោន ដែលក្នុងនោះរួមមាន អង្ករ កៅស៊ូ ចេកស្រស់ ស្វាយស្រស់ គ្រាប់ស្វាយចន្ទី គ្រាប់ពោត ម្ទេសស្រស់ និងម្រេច ។

❋ កម្ពុជានាំចេញជ័រកៅស៊ូបាន ៥២.៧១១តោន កើនឡើង ២៤ភាគរយ ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០ និងទទួលបានចំណូលជិត ៨៥លានដុល្លារអាមេរិក ។ ជ័រកៅស៊ូជាមធ្យមមានតម្លៃ ១.៦០៣ដុល្លារ ក្នុង ១តោន ធ្វើឲ្យចំណូលបានពីការនាំចេញជ័រកៅស៊ូក្នុងខែមករា ឆ្នាំ២០២១នេះ មានចំនួន ៨៤.៤៩៥.៧៣៣ ដុល្លារអាមេរិក ។ បច្ចុប្បន្នកម្ពុជាមានផ្ទៃដីផលិតជ័រកៅស៊ូចំនួន ៤០៤.១៥៩ ហិចតា ក្នុងនោះផ្ទៃដីចៀរជ័រចំនួន ២៩២.៤៩៧ហិចតា ស្មើនឹង ៧២% និងផ្ទៃដីថែទាំមានចំនួន ១១១.៦៦៣ហិចតា ស្មើនឹង ២៨% ។

❋ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ប្រមូលបានចំនួន ៨៧៩,៦៨ ប៊ីលានរៀល (ប្រមាណជា ២១៧,២០លានដុល្លារអាមេរិក) ធ្លាក់ចុះ ៨,០៦% បើប្រៀបធៀបរយៈពេលដូចគ្នា ឆ្នាំ២០២០ ។ ដោយឡែកចំណូលពីប្រភេទពន្ធ ០៣ នៅរក្សាកំណើនគួរឱ្យកត់សម្គាល់ក្នុងនោះ ពន្ធលើប្រាក់ចំណូលចំនួន ១៧៣,៧៩ប៊ីលានរៀល កើនឡើង ១១,៧៦ ប៊ីលានរៀល ប្រមាណ ៧,២៦%, អាករពិសេសចំនួន ៧៧,១០ ប៊ីលានរៀល កើនឡើង ៤,០៤ប៊ីលានរៀល ប្រមាណ ៥,៥៣% និងពន្ធលើប្រាក់បៀវត្សចំនួន ៩១,៣១ប៊ីលានរៀល កើនឡើង ៨,៣៥ ប៊ីលានរៀល ប្រមាណ ១០,០៧% ធៀបនឹងខែមករា ឆ្នាំ២០២០ ៕

វិស័យកសិកម្មនៅតែជាគោលដៅចំបង ដើម្បីធានាសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការនាំចេញ

ក្នុងឆ្នាំ២០២០ **វិស័យកសិកម្ម**បានដើរតួនាទីដ៏សំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ បង្កើនប្រាក់ចំណូលជូនប្រជាកសិករ និងបានចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ទោះបីស្ថិតក្នុងបរិបទនៃជំងឺឆ្លងកូវីដ-១៩ និងគ្រោះទឹកជំនន់នាពេលកន្លងមកក្តី។

ដើម្បីសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំប្រែក្លាយពីដំណាក់កាលអភិវឌ្ឍតាមបែបវិបុលវប្បកម្ម ឬតាមបែបប្រពៃណីឈានទៅរកដំណាក់កាលតាមបែបប្រពលវប្បកម្ម ដោយផ្អែកលើការប្រែប្រួលនៃបច្ចេកវិទ្យាថ្មីៗ ការស្រាវជ្រាវ ការអភិវឌ្ឍយន្តូបនីយកម្ម និងការបង្កើនសមត្ថភាពស្រោចស្រព ដើម្បីលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មដំណាំ រួមទាំងការចិញ្ចឹមសត្វ វារីវប្បកម្ម ការគ្រប់គ្រងដីធ្លី ធនធានព្រៃឈើ និងជលផល ព្រមទាំងការធានាចីរភាពធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ក្រសួងបានអនុវត្តវិធានការចាំបាច់មួយចំនួនរួមមាន ការកសាង និងនិងកែលម្អហេដ្ឋារចនា-សម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍ ព្រមទាំងការកសាងលិខិតបទដ្ឋានគតិយុត្ត និងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឲ្យមានប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២០ ផ្ទៃដីដាំដុះស្រូវសរុបទូទាំងប្រទេស សម្រេចបានចំនួន ៣,៤០៤លានហិកតា ស្មើនឹង១១២%នៃផែនការ ៣,០៤៨លានហិកតា ក្នុងនោះស្រូវរដូវប្រាំងមានចំនួន ០,៥៩៧លានហិកតា និងស្រូវរដូវវស្សាមានចំនួន២,៨០៧លានហិកតា។ផ្ទៃដីប្រមូលផលសរុបបានចំនួន៣,២៦៩លានហិកតា ក្នុងនោះស្រូវរដូវប្រាំងមានចំនួន០,៥៩២លានហិកតា និងស្រូវរដូវវស្សាមានចំនួន២,៦៧៧លានហិកតា។ បរិមាណផលស្រូវសរុបបានចំនួន ១០,៩៣៦លានតោន ក្នុងនោះបរិមាណផលស្រូវរដូវប្រាំងទទួលបាន២,៦១៦លានតោន និងបរិមាណផលស្រូវរដូវវស្សាទទួលបាន ៨,៣១៩លានតោន។ បើធៀបទៅនឹងឆ្នាំ២០១៩ បរិមាណផលស្រូវសរុបកើនឡើង ០,៤៦%។

-ផ្ទៃដីផលិតដំណាំសាកវប្បកម្មរយៈពេលខ្លីសម្រេចបាន១០២.៣២៤ហិកតា ស្មើនឹង១២៣% នៃផែនការចំនួន៨៣.៣០៣ហិកតា កើនលើសឆ្នាំ មុនចំនួន៧.៧៨៣ហិកតា។ ផ្ទៃដីប្រមូលផលសរុបសម្រេចបានចំនួន១០០.៥៣៤ហិកតា។ បរិមាណផលដំណាំសាកវប្បកម្មសរុបទទួលបាន១.០២០.២១៤ តោន លើសពីឆ្នាំមុនចំនួន១៤០.៥១៨តោន ។

*ឯកឧត្តម **វេង សាខុន** អញ្ជើញមកពិនិត្យកសិដ្ឋានចិញ្ចឹមត្រី ស្ថិតនៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ*

ដោយឡែកផ្ទៃដីដាំដុះដំណាំ សាកវប្បកម្មរយៈពេលវែងសម្រេចបាន ២៤៦.២៤៣ ហិកតា និងទទួលបានបរិមាណផលសរុបចំនួន ២.៩៩៣.២២៩តោន ដោយទទួលបានបរិមាណផលសរុបចំនួន៩៣៥.០៧២តោន ។

- ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបានមានចំនួន ៨៧៥.១៣៣ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន១៣.៥១២.៦៩៩តោន។ ដោយឡែក ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលវែងមានចំនួនសរុប ២៧២.៨៣០ហិកតា ដោយទទួលបានបរិមាណផលសរុប៣៦៦.១៣៧តោន ។

- ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបក្នុងឆ្នាំ២០២០ មានចំនួន ៣៤,៩៨ លានក្បាល ក្នុងនោះ គោ-ក្របីមានចំនួន៣,២៥លានក្បាល ជ្រូកចំនួន១,១លានក្បាល បក្សីចំនួន៣០,៥៥លានក្បាល។ បើប្រៀប-ធៀបឆ្នាំ២០១៩នៃផលិតកម្មសត្វសរុបកើនឡើង៩,២% ក្នុងនោះគោក្របីកើន១,៣% ជ្រូកកើន១០,៣% និងបក្សីកើន១០,០% ។ ដោយឡែកការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម សរុបមានចំនួន១៨,៩២ លានក្បាល ក្នុងនោះ គោ-ក្របីមានចំនួន១៣,៤២ពាន់ក្បាល ជ្រូកមានចំនួន ១,៣៧លានក្បាល បក្សីមានចំនួន១៧,៥០លានក្បាល។ ប្រៀបធៀបឆ្នាំ២០១៩ កើនឡើង៣៧% ក្នុងនោះ គោ ក្របី កើន៣៣,០% ជ្រូកកើន ១៩,៤% និងបក្សីកើន៣៨,៦% ។ ការចិញ្ចឹមត្រី-បង្គាអនុវត្តបានចំនួន៤០០.៤០០តោន និងការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន២៥០ លានក្បាល កើនឡើង៣០% គិតជាតម្លៃផលិតផលវារីវប្បកម្មមានចំនួន ៨០០ ៨០០ ០០០ ដុល្លារអាមេរិក។

ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានថ្លែងថា ក្នុងឆ្នាំ២០២០កម្ពុជាបាននាំចេញអង្ករសរុប ៦៩០.៨២៩តោន មានតម្លៃជិត៥៣៩លានដុល្លារ កើនឡើង ១១,៤០%

កម្ពុជាទទួលបានចំណូលជាង១២០០ លានដុល្លារ ពីការនាំចេញស្រូវជិត៣លានតោន និងអង្ករជិត៧០ម៉ឺនតោន នៅឆ្នាំ២០២០

បើធៀបនឹងឆ្នាំ២០១៩។ ចំពោះតម្លៃផលិតផលកសិកម្ម និងការនាំចេញក្រៅពីស្រូវ និងអង្ករ ក្នុងឆ្នាំ២០២០ មានចំនួនជាង៤,៤៩៣ពាន់លាន-ដុល្លារ, តម្លៃនៃការនាំចេញផលិតផលសរុបជាប្រភេទដំណាំក្រៅពីស្រូវ និងអង្ករមាន២,១៧ពាន់លានដុល្លារ។ យើងមានមោទនភាពចំពោះសមិទ្ធផលនៃការនាំចេញផលិតផលកសិកម្ម ហើយវាដល់ដំណាក់កាលមួយកំពុងមានការរីចម្រើនលើវិស័យកសិកម្ម ដោយបានឆ្លុះបញ្ចាំងពីលទ្ធភាពនៃការផ្គត់ផ្គង់ផលិតផល កសិកម្មរបស់យើងនៅលើទីផ្សារអន្តរជាតិ។

ជាមួយគ្នានឹងសមិទ្ធផលដែលសម្រេចបានខាងលើនេះ វិស័យកសិកម្មក៏នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា ផលិតកម្មដំណាំកសិកម្មនៅមានផលិតភាពទាប ការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម នៅមានកម្រិត ព្រមទាំងកង្វះការវិនិយោគលើការកែច្នៃ។ សមត្ថភាពមន្ត្រីរាជការ និងហេដ្ឋារចនាសម្ព័ន្ធនៃការងារស្រាវជ្រាវកសិកម្មនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង រួមទាំងការប្រមូលទិន្នន័យស្ថិតិតាមអនុវិស័យនីមួយៗមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ប្រព័ន្ធកសិកម្មនៅកម្ពុជាតែងតែ ទទួលរងនូវផលប៉ះពាល់ពីបាតុភូតធម្មជាតិនៃការប្រែប្រួលអាកាសធាតុ ពិសេសគ្រោះរាំងស្ងួត និងទឹក-ជំនន់ ។ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មក្នុងស្រុកពុំទាន់បានបំពេញគ្រប់គ្រាន់ទៅតាមតម្រូវការ និងការរកទីផ្សារលក់ផលិតផលកសិកម្មនៅជួបបញ្ហាថ្លៃដើមផលិតកម្ម និងការកែច្នៃនៅខ្ពស់។

ឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់ទិសដៅសម្រាប់ការអនុវត្តរួមមាន៖**១**- បន្តលើកកម្ពស់ការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកវិទ្យា និងបច្ចេកទេសកសិកម្មទំនើបក្នុងទិសដៅបង្កើនបរិមាណ គុណភាព អាហារូបត្ថម្ភ និងពិពិធកម្មផលិតផលកសិកម្មប្រកបដោយនិរន្តរភាព។ពង្រឹងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម និងអភិវឌ្ឍន៍ធនធានមនុស្សគ្រប់កម្រិតសញ្ញាបត្រ និងជំនាញវិជ្ជាជីវៈ និងជាពិសេសបង្កើនចំនួនអ្នកស្រាវជ្រាវ និងអ្នកវិទ្យាសាស្ត្រកសិកម្ម។ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មថ្មីៗប្រកបដោយនវានុវត្តន៍ និងមានលក្ខណៈបច្ចេកវិទ្យាឌីជីថល ការអនុវត្តកសិកម្មល្អ ការរៀបចំកំណត់តំបន់ដាំដុះ ការរៀបចំផែនការដាំដុះទៅតាមតម្រូវការទីផ្សារ ការកែលម្អការគ្រប់គ្រង និងប្រើប្រាស់ធនធានដីប្រកបដោយចីរភាព ការកែលម្អប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងទឹកតាមរយៈប្រព័ន្ធសន្សំសំចៃទឹក ការប្រើប្រាស់យន្តូបនីយកម្មកសិកម្ម និងបច្ចេកវិទ្យាក្រោយប្រមូលផល ការលើកកម្ពស់គុណភាពនៃការផ្ដល់សេវាផ្សព្វផ្សាយកសិកម្ម ឲ្យបានដល់កសិករ និងសហគមន៍កសិកម្ម ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យពូជដំណាំកសិកម្ម និងធាតុចូលកសិកម្ម ពង្រីកសមត្ថភាពមន្ទីរពិសោធន៍ជាតិ កសិដ្ឋានផលិតពូជដំណាំ និងស្ថានីយ មជ្ឈមណ្ឌល ស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មឲ្យបានល្អប្រសើរ, **២**-ជំរុញការធ្វើពិពិធកម្មកសិកម្មទៅរកផលិតផលដែលមានតម្លៃបន្ថែមខ្ពស់ និងមានសក្ដានុពលលើដំណាំបសុសត្វ វារីវប្បកម្ម ផលិតផលឈើដាំ និងការវិនិយោគលើការកែច្នៃកសិផលសំខាន់ៗ ដោយត្រូវបន្តលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ការកែច្នៃវេចខ្ចប់ និងពង្រឹងសមត្ថភាពពិសោធន៍ ស្តង់ដារគុណភាពតាមរយៈគោលការណ៍អនុវត្តកសិកម្មល្អ(GAP) ការអនុវត្តការចិញ្ចឹមសត្វល្អ(GAHP) ការអនុវត្តវារីវប្បកម្មល្អ(GAqP) ក៏ដូចជាពង្រឹងវិធានការការពារដំណាំ សុខភាពសត្វ និងគុណភាពផលិតផលសត្វ និងផលិតផលជលផល អនាម័យនិងភូតគាមអនាម័យ (SPS) និង**ទី៣**-ជំរុញការ ចិញ្ចឹមសត្វរបស់កសិករឲ្យទៅជាការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្ម ជាពិសេសការចិញ្ចឹមគោពូជកូនកាត់ដែលមានផលិតភាពខ្ពស់ ដើម្បីបង្កើនប្រាក់ចំណូល ព្រមទាំងលើកទឹកចិត្តដល់ការចិញ្ចឹមសត្វខ្នាតតូច មធ្យម និងខ្នាតធំដែលមានផលិតភាពខ្ពស់ ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់ការនាំចេញ។ គ្រប់គ្រងការធ្វើអាជីវកម្មសត្វរស់ផលិតផលសត្វចំណីសត្វបសុឱសថ និងធាតុចូលផ្សេងៗ ដោយមិនឲ្យមានការធ្វើអាជីវកម្មផ្ដាច់មុខដែលប៉ះពាល់ដល់តម្លៃនិងបញ្ហាទីផ្សារ។បន្តជំរុញការកែច្នៃផលិតផលសាច់ ដោយត្រូវគ្រប់គ្រងសត្តឃាតដ្ឋាន កន្លែងពិឃាតសត្វ និងកន្លែងកែច្នៃ ឲ្យអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល និងមានការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វ ធានាបាននូវគុណភាព អនាម័យ និងសុវត្ថិភាពសាច់សម្រាប់ធានាតម្រូវការក្នុងស្រុកនិងឆ្ពោះទៅរកការនាំចេញទៅបរទេស។ បន្តពង្រឹងការត្រួតពិនិត្យ អនាម័យសត្វ និងផលិតសត្វ ដើម្បីបង្ការការពារជំងឺឆ្លងសត្វ ជំងឺស៊ូណូសផលិតផលសត្វប្រកបដោយសុវត្ថិភាព និងគ្រប់គ្រងហានីភ័យជំងឺរាតត្បាតនានាជាយថាហេតុ។

សរុបមក ការជំរុញកំណើនវិស័យកសិកម្មនៅតែជាគោលដៅចម្បងដើម្បីធានាសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការនាំចេញ។ គោលដៅនេះ អាចសម្រេចបានដោយសារគោលនយោបាយវិត្តារកម្មរបស់រាជ-រដ្ឋាភិបាល ក្នុងការវិនិយោគបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យកសិកម្ម ការស្រាវជ្រាវ ការប្រើប្រាស់ពូជថ្មីៗ ការផ្សព្វផ្សាយបច្ចេកទេសដើម្បីដើរតាមឲ្យទាន់បរិបទនៃសាកលភាវូបនីយកម្ម រួមទាំងការចូលរួមកាន់តែសកម្មជាងមុនពីសំណាក់ដៃគូអភិវឌ្ឍ និងវិស័យឯកជន ក្នុងការវិនិយោគលើវិស័យកសិកម្ម ៕

ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មឲ្យកាន់តែមានសន្ទុះខ្លាំងក្នុងឆ្នាំ ២០២១

*ឯកឧត្តម **ប៉ាន សូរស័ក្តិ** ចង្អុលបង្ហាញការងារជូនមន្ត្រីមន្ទីរពាណិជ្ជកម្ម និង មន្ត្រីសាខាការពារអ្នកប្រើប្រាស់កិច្ចការ ប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.) ខេត្តពោធិ៍សាត់*

នៅក្នុងឆ្នាំ ២០២០ ទោះបីជាស្ថិតក្នុងកាលៈទេសៈប្រឈមរំខានដោយសារកូវីដ១៩ និងការរាំងស្ទះខ្លះៗពីទីផ្សារគោលដៅមួយចំនួនក្តី ប៉ុន្តែការអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្មនៅតែមានដំណើរការល្អប្រសើរ ។

តាមរយៈការជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញ និងពង្រីកទីផ្សារក្នុងប្រទេសសំដៅជំរុញកំណើនសេដ្ឋកិច្ច និងបង្កើនល្បឿនសមាហរណកម្មសេដ្ឋកិច្ច-ពាណិជ្ជកម្មតំបន់ និងពិភពលោក ក្រសួងពាណិជ្ជកម្មបានសម្រេចនូវសមិទ្ធផលសំខាន់ៗរួមមាន៖ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០ ដោយគ្រោងដាក់ឲ្យចូលជាធរមានក្នុងឆ្នាំ ២០២១នេះ ដែលតាមរយៈនេះ ការនាំចេញទៅកាន់ទីផ្សារចិននឹងសង្ឃឹមថា កើនឡើង ២៥% ក្នុងមួយឆ្នាំ ក្នុងនោះ មានកសិផល និងផលិតផលកែច្នៃរបស់កម្ពុជា រួមផ្សំនឹងការវិនិយោគក្នុងស្រុក និងពីបរទេសក៏នឹងកើនឡើងជាលំដាប់។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីគ្រប់ជ្រុងជ្រោយ តំបន់ (RCEP) កាលពីថ្ងៃទី ១៥ វិច្ឆិកា ឆ្នាំ ២០២០ កម្ពុជានឹងរំពឹងថា អាចមានកំណើនប្រចាំឆ្នាំលើការនាំចេញប្រមាណ ៧,៣% ការវិនិយោគប្រមាណ២៣,៤%និងផលិតផលក្នុងស្រុកសរុប(ផ.ស.ស)ប្រមាណ ២% បន្ថែមលើ ផ.ស.ស ដែលកម្ពុជា មាននាពេលបច្ចុប្បន្ន។ ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ បានសម្រេចបញ្ចប់ជាស្ថាពរនៅដើមឆ្នាំ ២០២១នេះ ហើយនៅពេលកិច្ចព្រមព្រៀងនេះដំណើរការជាផ្លូវការនឹងជំរុញកំណើននាំចេញនូវផលិតផលកម្ពុជាទៅទីផ្សារកូរ៉េកាន់តែប្រសើរឡើង ។ ឆ្នាំ២០២០ ទំហំពាណិជ្ជកម្មអន្តរជាតិសម្រេចបានប្រមាណ៣២.០០០លានដុល្លារក្នុងនោះការនាំចេញមានទឹកប្រាក់ ១៥.៧៤៨ លានដុល្លារ កើនឡើង ១៦,២៩% និងការនាំចូលមានទឹកប្រាក់ ១៦.២៥២ លានដុល្លារ ។ គួរកត់សម្គាល់ថា ការនាំចេញផលិតផលកសិកម្មសម្រាប់ទំនិញ ៧ មុខមាន ៣.៨៨១ លានដុល្លារ ក្នុងនោះការនាំចេញអង្ករសម្រេចបាន៦៩០.៨២៩តោនកើន ១១,៤% ធៀបនឹងឆ្នាំ២០១៩ មានតម្លៃ សរុបជាង៥៣៨ លានដុល្លារ ឯការនាំចេញស្រូវក្រៅផ្លូវការមានចំនួន ២,៨៩៣ លានតោន មានតម្លៃសរុបជាង៧២៣ លានដុល្លារ ។ ដោយឡែកការនាំចេញផលិតផលកៅស៊ូសម្រេចបាន ៣៤០.០០០តោន មានតម្លៃសរុប ៤៥៩ លានដុល្លារ ធៀបនឹងការនាំចេញជិត ៣០០.០០០តោន និងមានតម្លៃសរុបជិត ៤០០ លានដុល្លារនៅឆ្នាំ ២០១៩ ។

ក្នុងឆ្នាំ ២០២០កន្លងទៅនេះដែរ ក្រសួងពាណិជ្ជកម្ម បានចូលរួមក្នុងកម្មវិធីសម្រួលពាណិជ្ជកម្មក្រោមកម្មវិធីបញ្ជាតែមួយជាតិ(National Single Window) ក្នុងដំណាក់កាលទី១ និងទី២ ដោយអនុវត្តការចេញវិញ្ញាបនបត្រប្រភពដើមទំនិញជាអេឡិចត្រូនិក សម្រាប់ការធ្វើពាណិជ្ជកម្មក្នុងតំបន់អាស៊ាន និងការផ្តល់អាជ្ញាបណ្ណនាំចេញ នាំចូលវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃ និងបានអនុវត្តការចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលបច្ចេកវិទ្យារួម (CAM DX) ដែលអាចភ្ជាប់ព័ត៌មានជាមួយអគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយទទួលបានការចុះបញ្ជីតែក្នុងរយៈពេល ៣ ថ្ងៃប៉ុណ្ណោះ និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិបញ្ញា (IPAS4) ។ ក្រសួងបានធ្វើការចុះបញ្ជីក្រុមហ៊ុន មូលធន ៥ ០៩៤ , ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ៤៦, សហគ្រាស ១ ៩៦៥, សាខាក្នុងស្រុក ៦២៩ និងចុះបញ្ជីកែប្រែផ្លាស់ប្តូរភាគហ៊ុន ១១ ៦៧១ ។ ក្នុងការរក្សាស្ថិរភាពថ្លៃ និងការជំរុញពាណិជ្ជកម្មក្នុងប្រទេសក្រសួងបានជំរុញពង្រឹងបន្ថែមយន្តការតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ថ្លៃទំនិញ និងសន្និធិទំនិញចាំបាច់ ស្រូវ អង្ករ ប្រេងឥន្ធនៈ និងការធ្វើពាណិជ្ជកម្មទំនិញនៅតាមព្រំដែន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ ជំរុញនូវយន្តការដោះស្រាយបញ្ហាជូនដល់ប្រជាកសិករ និងផលិតករដោយផ្តោតលើផលិតផល សក្តានុពលចំនួន ៥ មុខ រួមមាន មាន់ បន្លែ ដំឡូង ស្រូវប្រណិត និងសូត្រ ដោយបង្កើតផ្សារចុះសប្តាហ៍នៅតាមបណ្តាខេត្តទាំង១៨ ព្រមទាំងឧបត្ថម្ភទុនផ្តល់កម្ចីនិងកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រតាមរយៈគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) ដែលអនុវត្តដោយក្រសួងពាណិជ្ជកម្ម និងជំរុញនូវការចូលរួមរក្សាស្ថិរភាពថ្លៃប្រេងឥន្ធនៈ អង្ករ និងទំនិញយុទ្ធសាស្ត្រមួយចំនួន តាមរយៈការជំរុញឲ្យបណ្តាស្ថានីយបង្ហាញថ្លៃប្រេង ជាសាធារណៈរៀងរាល់ថ្ងៃ។ ការទិញលក់អង្ករក្នុងស្រុក ដោយសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាទប់ស្កាត់ ការដំឡើងថ្លៃអង្ករ រក្សាស្ថិរភាពថ្លៃស្រូវ និងធ្វើអន្តរាគមន៍ទីផ្សារទំនិញចាំបាច់មួយចំនួន ដែលបម្រើឲ្យសេចក្តីត្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់ ។

ទោះបីជាមានការប្រឹងប្រែងរហូតបានសម្រេចនូវលទ្ធផលគួរជាទីមោទនក្តី ក៏ប៉ុន្តែការអនុវត្តការងារក្នុងវិស័យពាណិជ្ជកម្មនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលទាមទារឲ្យមានការព្យាយាម និងស្វែងរកដំណោះស្រាយបន្ថែមទៀត ដែលបញ្ហាប្រឈមទាំងនោះរួមមាន ៖ ដោយការរាតត្បាតនៃជំងឺកូវីដ-១៩ បណ្តាលឲ្យការចរចា និងការចុះកិច្ចព្រមព្រៀងមួយចំនួនត្រូវបានលើកពេល ។ កង្វះថវិកា និងធនធាន

បុគ្គលិកត្រួតពិនិត្យមើល អង្ករ នៅក្នុងក្រុមហ៊ុននាំចេញមួយ

មនុស្ស ដែលមានសមត្ថភាពសម្រាប់ការកសាងច្បាប់ ការចរចា ការសិក្សាលទ្ធភាពកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្មអន្តរជាតិនានា ជូនស្ថាប័នពាក់ព័ន្ធ និងធុរជនសម្រាប់ការអនុវត្ត ។ កង្វះថវិកា និងធនធានមនុស្ស ដើម្បីកសាងគោលនយោបាយយុទ្ធសាស្ត្រជំរុញពាណិជ្ជកម្ម និងគោលនយោបាយអភិវឌ្ឍផលិតផលតាមវិស័យ។ កិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធនៅមានកម្រិតក្នុងការសម្របសម្រួលពាណិជ្ជកម្ម សុវត្ថិភាពម្ហូបអាហារ និងកិច្ចការពារអ្នកប្រើប្រាស់នាំឲ្យប្រសិទ្ធភាពការអនុវត្តច្បាប់ និងគោលនយោបាយមិនទាន់បានល្អ ។ សមត្ថភាពមន្ទីរពិសោធន៍នៅមានកម្រិត ខ្វះមន្ទីរពិសោធន៍ខ្នាតតូច សម្ភារៈ និងឧបករណ៍ពិសោធន៍ ។ លិខិតបទដ្ឋានសម្រាប់គាំទ្រសម្រាប់អនុវត្តការងារមិនគ្រប់គ្រាន់ នាំឲ្យការត្រួតពិនិត្យគុណភាពទំនិញ សុវត្ថិភាព ម្ហូបអាហារសម្រាប់ការពារអ្នកប្រើប្រាស់ និងការធានាភាពប្រកួតប្រជែងទីផ្សារនៅមានកម្រិត ។ កង្វះហេដ្ឋារចនាសម្ព័ន្ធគាំទ្រសម្រាប់វិស័យស្រូវអង្ករដូចជា ឃ្លាំងស្តុក ឡសម្ងួត រោងម៉ាស៊ីនកែច្នៃ ។ ការចូលរួមអនុវត្តក្នុងកម្មវិធី បញ្ជរតែមួយជាតិ និងថ្នាលចុះបញ្ជីរួមដោយបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត ដែលជាហេតុបណ្ដាលឲ្យការធ្វើពាណិជ្ជកម្មនៅមានបញ្ហាដូចជា ប្រើប្រាស់រយៈពេលច្រើន និងថ្លៃដើមខ្ពស់ ។

ក្នុងទិសដៅអនុវត្តបន្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់គណបក្សឈានទៅសម្រេចបានសមិទ្ធលថ្មីៗថែមទៀតក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងចូលរួមចំណែកបង្កើនល្បឿនសេដ្ឋកិច្ចជាតិ ដើម្បីតាមឲ្យទាន់សភាពការណ៍វិវត្តន៍សេដ្ឋកិច្ចតំបន់ និងពិភពលោក ក្រសួងបានដាក់ទិសដៅភារកិច្ចរួមមាន៖ ក្រសួងពាណិជ្ជកម្ម បាននឹងកំពុងត្រៀមបន្តចរចា និងសិក្សា ដើម្បីបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី និងទ្វេភាគីជាមួយ សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) ឥណ្ឌា, រុស្ស៊ី, ជប៉ុន, ម៉ុងហ្គោលី ជាដើម ដើម្បីពង្រីក និងធ្វើពិពិធកម្មទីផ្សារនាពេលខាងមុខទៀត ។ បន្តធ្វើវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ បន្តយន្តការតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មគ្រប់ប្រភេទ ថ្លៃទំនិញ និងសន្និធិទំនិញចាំបាច់ប្រចាំជីវភាព ការស្តុកស្រូវ-អង្ករតាមបណ្ដាខេត្ត ថ្លៃប្រេងឥន្ធនៈ និងចរន្តទំនិញនៅតាមព្រំដែនទូទាំងប្រទេស តាមរយៈប្រព័ន្ធបច្ចេកទេសវិទ្យាព័ត៌មាន។ ស្នើសុំការផ្តល់សច្ចាប័នកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន, កិច្ចព្រមព្រៀង RCEP និងកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងដែន ដោយពុំប្រើប្រាស់ក្រដាសស្នាមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ។ បន្តរៀបចំយុទ្ធនាការទិញផលិតផលខ្មែរតាមបណ្ដាខេត្ត ដើម្បីភ្ជាប់ទំនាក់ទំនងមូលដ្ឋានផលិតកម្មជាមួយទីផ្សារ និងបំផុសមហាជនឲ្យគាំទ្រប្រើប្រាស់ផលិតផលខ្មែរកាន់តែទូលំទូលាយ ។ បន្តចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ និងរៀបចំមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស ដើម្បីបង្ហាញផលិតផលខ្មែរ និងពង្រីកទីផ្សារក្រៅប្រទេសសម្រាប់ទាក់ទាញវិនិយោគ និងទេសចរណ៍។ បន្តរៀបចំគោលនយោបាយតាមវិស័យ និងចង្កោមទំនិញ, រៀបចំមជ្ឈមណ្ឌលអភិវឌ្ឍសិប្បកម្មកម្ពុជា តាមគោលនយោបាយភូមិមួយផលិតផលមួយ ដើម្បីឈានទៅកសាងម៉ាកសមូហភាព និងដើម្បីពិនិត្យលទ្ធភាពបង្កើតម៉ាក សម្គាល់ភូមិសាស្ត្រតាមបណ្ដាខេត្តដែលមានឯកទេសកម្មផលិត ។ ជំរុញអនុវត្តពេញលេញកូតានាំចេញអង្ករទៅ ទីផ្សារចិនឲ្យមានប្រសិទ្ធភាពតាមរយៈការរក្សាគុណភាព និងផ្តោតលើម៉ាកសញ្ញាអង្ករដែលមានគុណភាពស្រាប់ គឺ□ម្លិះអង្ករ□តាមទីផ្សារលក់រាយក្នុងស្រុកចិន។ជំរុញការនាំចេញអង្ករទៅអង់គ្លេស ដើម្បីទាញប្រយោជន៍អនុគ្រោះ GSP ក្រោយអង់គ្លេសចេញពី EU និងធានាស្ថិរភាពថ្លៃអង្ករក្នុងស្រុក និងបន្តរក្សាសន្និធិស្បៀងបម្រុងរដ្ឋសម្រាប់ទប់ទល់គ្រោះហានិភ័យ ។

ដើម្បីធ្វើឲ្យទទួលបានជោគជ័យក្នុងបណ្ដាភារកិច្ច និងទិសដៅការងារក្នុងពេលខាងមុខ ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានចង្អុលបង្ហាញការងារអាទិភាពមួយចំនួនគឺ៖ មន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ត្រូវបញ្ចៀសដាច់ខាតការទាមទារកម្រៃសេវាក្រៅផ្លូវការពីអាជីវករ ពាណិជ្ជករ ផលិតករ អ្នកនាំចេញ និងសេវាផ្សេងៗ ដែលផ្ទុយពីខ្លឹមសារប្រកាសរួមស្តីពីកម្រងសេវាសាធារណៈរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ត្រូវបន្តខិតខំយកចិត្តទុកដាក់ក្នុងការពង្រីកចំណេះដឹងរបស់ខ្លួនបន្ថែមទៀត ទាំងកម្រិតជំនាញ និងភាសាបរទេស តាមរយៈការសិក្សាបន្ថែម ការស្រាវជ្រាវ និងដកស្រង់នូវបទពិសោធន៍ពីមន្ត្រីដែលមានសមត្ថភាព និងជាពិសេសរួមសហការគ្នាចុះផ្សារត្រួតពិនិត្យ សុវត្ថិភាព ផលិតផល ទំនិញ គ្រឿងឧបភោគ បរិភោគ ឱ្យកាន់តែស្វាហាប់ ដើម្បីការពារសុខភាពរបស់ប្រជាពលរដ្ឋ ឱ្យដូចជាការពារសុខភាពបងប្អូន កូនចៅរបស់ខ្លួនឯងដែរ។ ត្រូវបន្តពង្រឹងបន្ថែមយន្តការតាមដាន និងត្រួតពិនិត្យការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ថ្លៃទំនិញ និងសន្និធិទំនិញចាំបាច់ ស្រូវ-អង្ករ ប្រេងឥន្ធនៈ និងការធ្វើពាណិជ្ជកម្មទំនិញនៅតាមព្រំដែន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងជំរុញយន្តការដោះស្រាយរាល់បញ្ហាដល់កសិករ ផលិតករ ដោយផ្តោតលើផលិតផលសក្តានុពលចំនួន ៥មុខ មាន់ស្រែ បន្លែ ដំឡូង ស្រូវប្រណិត និងសូត្រ ដោយបង្កើតផ្សារចុងសប្តាហ៍ ។ ពេលចុះអនុវត្តន៍ការងារ និងនៅក្នុងជីវភាពប្រចាំថ្ងៃក្នុងស្ថានភាពថ្មីនៃជំងឺកូវីដ-១៩ នាពេលនេះ មន្ត្រីយើងទាំងអស់គ្នាត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងសុខាភិបាល ។ ត្រូវបន្តធ្វើសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរាល់គោលការណ៍ លិខិតបទដ្ឋានច្បាប់ និងកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេសរបស់ក្រសួងពាណិជ្ជកម្ម សំដៅជួយសម្រួលពាណិជ្ជកម្ម ជំរុញការនាំចេញ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋកាន់តែល្អ ៕

ប្រវត្តិរូបសំណាក
ដំរីជាន់ខ្លាខេត្តកំពង់ធំ



បើយើងធ្វើដំណើរតាមផ្លូវជាតិលេខ ៦ ពីភ្នំពេញឆ្ពោះទៅខេត្តកំពង់ធំ មុននឹងឃើញទិដ្ឋភាពទីរួមខេត្ត យើងនឹងប្រទះឃើញរូបសំណាកដំរីជាន់ខ្លា ស្ថិតនៅខាងស្តាំដៃក្នុងសួនច្បារក្នុងរាងច្រមុះជ្រូក។ រូបសំណាកដំរីជាន់ខ្លានេះសាងសង់ឡើងនៅឆ្នាំ១៩៦៥ដោយសិល្បករនៃសកលវិទ្យាល័យសូន្យរូប ក្រោមការណែនាំរបស់លោកគ្រូ □**តុងហាវ**□ អតីតអភិបាលខេត្ត កំពង់ធំ។

ព្រះតេជគុណព្រះនាម តុងហាវ អតីតចៅហ្វាយ ខេត្តកំពង់ធំ ក្នុងទសវត្សរ៍ទី៦០ ជាម្ចាស់រូបសំណាកដំរីជាន់ខ្លាបានសុគតនៅរាត្រីថ្ងៃទី២៣ខែវិច្ឆិកាឆ្នាំ២០១៦នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញក្នុងព្រះជន្មាយុ១០២ព្រះវស្សា។ បច្ចុប្បន្នរូបសំណាកដំរីជាន់ខ្លាត្រូវបានរៀបចំជួសជុលកសាងជាថ្មីឡើងវិញ។ លោក **ហុក រិន** គណៈកម្មការកសាងបញ្ជាក់ថា ការរៀបចំនេះដើម្បីលើករូបសំណាកឲ្យបានខ្ពស់ជាងមុន និងរៀបចំធ្វើសួនច្បារឲ្យមានសោភ័ណភាពស្រស់ស្អាតជាងមុនផងដែរ។

តាមការបំភ្លឺពីមន្ត្រីនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំបានឲ្យដឹងថា អត្ថន័យជានិមិត្តរូបនៃរូបសំណាកដំរីជាន់ខ្លា នេះមានចំណុចធំៗសំខាន់ពីរយ៉ាង៖ -**ចំណុចទី១** គឺជាប្រវត្តិភូមិសាស្ត្ររបស់ខេត្ត - **ចំណុចទី២** គឺជាជំនឿអក្សរសិល្ប៍ក្នុងចលនាព្រហ្មនិយម។

រូបសំណាកនេះ ប្រកបទៅដោយសិល្បៈកម្រិតខ្ពស់ តាមលក្ខណៈភូមិសាស្ត្ររបស់ខេត្តកំពង់ធំ បង្កប់ជាមួយអត្ថន័យអក្សរសិល្ប៍។រូបសំណាកនេះធ្វើអំពីស៊ីម៉ង់មានកម្ពស់ និងទំហំប៉ុនគ្នានឹងដំរីពិតពេញវ័យមធ្យមមួយឈរលើកម្រាលដ៏ក្រាស់ ជើងមុខខាងស្តាំជាន់លើពោះខ្លា ដែលដេកផ្ងារជើងស្រវាចាប់ជើងដំរីជាប់ស្អិតប្រៀបដូចកំពុងប្រយុទ្ធគ្នា និងមានសត្វខ្លាមួយទៀតមកទំលើខ្នងដំរីហែកខាំក្រញីយ៉ាងកាចសាហាវ ដោយបែរមុខឆ្ពោទៅទិសនិរតីក្នុងសភាពភ័យស្លន់ស្លោ។ រូបសំណាកក៏បានបង្ហាញពីលក្ខណៈភូមិសាស្ត្រ ប្រកបដោយវិសាលភាពដ៏ធំធេងរបស់ខេត្តដែលសម្បូរទៅដោយធនធានធម្មជាតិដូចជា សត្វព្រៃ ព្រៃឈើ ស្ទឹងបឹងបួរក្រមថ្ម និងប្រាសាទបុរាណពាស-ពេញក្នុងតំបន់។អត្ថន័យមួយទៀតរូប សំណាកនេះ ធ្វើឡើងដើម្បីបម្រើចលនាអក្សរសិល្ប៍ដែលដកស្រង់ចេញពីរឿងរាមកេរ្តិ៍ត្រង់ឈុតមួយរបស់តួអង្គ ឥន្ទជិតដែលធ្វើសង្គ្រាមជា មួយនឹងព្រះរាម ព្រះល័ក្ខបន្ទាប់ពីទទួលបរាជ័យគ្រប់សមរភូមិរបស់ក្រុងរាប ព្រះចៅក្រុងអលង្កាបានចាត់បុត្ររបស់ខ្លួនឈ្មោះ ឥន្ទជិត ដឹកនាំទ័ពយក្សទៅប្រយុទ្ធ ជាមួយព្រះរាមព្រះល័ក្ខបន្ទាប់ពីទទួលបរាជ័យទៀត ឯពលសេនាក៏ស្លាប់វិនាសស្ទើរតែអស់។ឃើញដូច្នោះឥន្ទជិតក៏ប្រើឧបាយ-កលកាឡាខ្លួនជាដំរីមួយដ៏ធំ និងមានក្បូនដង្ហែរយ៉ាងគគ្រឹកគគ្រេងដើម្បីបង្ហាញគូសត្រូវឲ្យកោតស្ញប់ស្ញែង។ ស្វាហនុមានបានដឹងពីឧបាយកលក៏បានក្លែងខ្លួនជាសត្វខ្លាមួយដ៏ធំដើម្បីតតាំងជាមួយនឹងដំរីឥន្ទជិតនោះដំរីឃើញខ្លាក៏ពុំបានដឹងថា ជាហនុមានក៏បម្រុងលើកជើងជាន់ឲ្យសូន្យជីវិតនៅគ្រានោះ។ ប៉ុន្តែខ្លាហនុមានបានស្រវាចាប់ និងខាំជើងដំរីឥន្ទជិតជាប់ធ្វើឲ្យវាបាត់បង់ក្នុងការប្រយុទ្ធ។ ពេលនោះដែលស្វាអង្គត់ក៏បានកាឡាខ្លួនជាខ្លាមួយទៀតដែរលោតហក់ទៅជិះនៅលើខ្នងដំរីហើយខាំក្រញីហែកសាច់ដាច់ទាំងដុំៗស្រែករំពងពេញព្រៃ។ ពេលនោះព្រះរាមក៏លើកធ្នូបាញ់ដំរីឥន្ទជិតស្លាប់ក្នុងពេលនោះទៅ។

អត្ថន័យក្នុងរូបសំណាក ដំរីជាន់ខ្លាដែលទាក់ទងនឹងអក្សរសិល្ប៍ ក៏បានសង្ខេបបញ្ជាក់ត្រង់ចំណុចនោះឯង។

ខេត្តកំពង់ធំជាឈ្មោះខេត្តមួយនៃប្រទេសកម្ពុជា។ កំពង់ធំជាខេត្តមួយស្ថិតនៅចំកណ្តាលនៃផ្ទៃប្រទេសមានទីរួមខេត្តឈ្មោះក្រុងកំពង់ធំស្ថិតនៅតាមបណ្តោយនៃច្រាំងស្ទឹងសែន ។ ខេត្តនេះមានផ្ទៃដីសរុប ១៣៨១៤គីឡូម៉ែត្រការ៉េ បែងចែកជា ៨ក្រុងស្រុក មាន ៨១ឃុំសង្កាត់ និង៧៣៤ភូមិ។ ក្រុមប្រាសាទសម្បូរព្រៃគុកមានប្រាសាទសរុបជិត ២០០ផ្សេងទៀតដោយមានសក្តានុពលសំខាន់សម្រាប់សិក្សាស្រាវជ្រាវពីអរិយធម៌ខ្មែរ។

ប្រវត្តិនៃខេត្តកំពង់ធំ មានរឿងតំណាលតគ្នាពីបុរាណមកថា:(**កំពង់ពស់ធំ**)ជាឈ្មោះដើមកំណើតនៃខេត្តកំពង់ធំ។កាលពីយូរលង់ណាស់មកហើយ នៅកំពង់ទឹកក្បែរមាត់ស្ទឹង-សែន មានរូងថ្មមួយយ៉ាងធំ នៅក្នុងរូងថ្មនោះមានពស់ញីឈ្មោលមួយគូរស់នៅទីនោះ ។ ប្រជារាស្ត្ររស់នៅក្បែរនោះ ក៏បានឃើញញឹក-ញាប់រៀងរាល់ថ្ងៃសីលម្តងៗ។ ដោយសារមានការបាត់សត្វពាហនៈ ញឹកញាប់ក្រោយមកដោយមានការភ័យខ្លាចរបស់អ្នកស្រុកពួកគេនាំគ្នាយកដុំថ្មធំៗ ទៅដាក់បិទខ្ទប់មាត់រូងធ្វើឲ្យសត្វពស់ធំៗទាំងពីរនោះលែងឃើញបង្ហាញខ្លួននៅមាត់កំពង់នោះរហូតមក ។ ទីនោះពួកអ្នកស្រុកហៅថា កំពង់ពស់ធំ ក្រោយមកក៏ក្លាយឈ្មោះថា **កំពង់ធំ** និងក្លាយជាឈ្មោះ ខេត្ត **កំពង់ធំ** រហូតមកដល់សព្វថ្ងៃនេះ ៕

ឯកសារ
មន្ទីរវប្បធម៌វិចិត្រសិល្បៈ
ខេត្តកំពង់ធំ

ការព្យាករណ៍កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០២១ នៅតែមិនទាន់ប្រាកដប្រជា

វិបត្តិសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២០ដែលបង្កឡើងដោយជំងឺកូវីដ-១៩ គឺជាវិបត្តិដ៏ធ្ងន់ធ្ងរបំផុត គិតចាប់ពីវិបត្តិសេដ្ឋកិច្ចសកលនៅឆ្នាំ១៩២៩មក។ លោកស្រី Kristalina Georgieva អគ្គនាយកអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិធ្លាប់បានធ្វើការព្យាករណ៍សេដ្ឋកិច្ចកាលពី ៣ឆ្នាំមុនថា កំណើនសេដ្ឋកិច្ចនឹងជួយលើកកម្ពស់ជីវភាពរបស់ប្រជាជន នៅតាមប្រទេសប្រមាណ១៦០ ប៉ុន្តែក្នុងឆ្នាំ ២០២០ ក្ដីសង្ឃឹមបានរលាយសូន្យ ព្រោះប្រជាជននៅតាមប្រទេសចំនួន ១៧០ត្រូវប្រឈមនឹងការបាត់បង់ប្រាក់ចំណូល។វិបត្តិសេដ្ឋកិច្ចបង្កឡើងដោយជំងឺរាតត្បាតកូវីដ-១៩មានទំហំកាន់តែធំ ព្រោះគ្មាននរណាម្នាក់អាចស្មានបានទេថាបញ្ហាជំងឺឆ្លងនេះនឹងចប់នៅពេលណា។ សម្រាប់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺបានត្រឹមសង្ឃឹមទាំងមិនច្បាស់ថា សកម្មភាពសេដ្ឋកិច្ចអាចដំណើរការល្អវិញចាប់ពីពាក់កណ្ដាលឆ្នាំ ២០២១។

